# និព្វានទៅឯណា?



ភិក្ខុធម្មបាល ខៀវ ជុំ

ព.ស. ២៥១៧ គ.ស. ១៩៧៣

ភិក្ខុធម្មបាល ខៀវ ជុំ មានឥទ្ធិពលនយោបាយខ្លាំងក្នុងសម័យសាធារណរដ្ឋខ្មែរ មកពីមានការទាក់ទងជាមួយអ្នកនយោបាយក្រុមនេះពីដើម ។ ព្រះអង្គតែងតែសម្តែងមតិនយោបាយតាមរយៈវិទ្យុជាតិ ។ ព្រះអង្គមានជំនឿថាប្រទេសខ្មែរបានទទួលទុក្ខវេទនាអំពី "អំណាចផ្តាច់ការ អត្តនោមត្តិ រាប់ពាន់ឆ្នាំមកហើយ" ។ ប្រជាជនខ្មែរ គួរតែទទួលយកព្រលឹងប្រជាធិបតេយ្យស្មារតីយុត្តិធម៌ គោលការសាធារណរដ្ឋ ដែលព្រះពុទ្ធបរមគ្រូបានអនុវត្តន៍ ។

គណសង្ឃរួមទាំងសម្តេចព្រះសង្ឃរាជ ហួត តាត បានរិះគន់និងព្រមានភិក្ខុធម្មបាល ខៀវ ជុំ អំពីសកម្មភាពឡូកឡំក្នុងឆាកនយោបាយ ។ ព្រះអង្គបានតបថា ក្នុងឋានៈព្រះអង្គជាសង្ឃដែលមានភារៈប្រោសសត្វលោកមិនអាចគេចវេសពីនយោបាយដែលទាក់ទងជានិច្ចដល់សុខទុក្ខរបស់ប្រជាពលរដ្ឋ ។

ក្នុងឆ្នាំ១៩៧៥ ពេលទមិឡខ្មែរក្រហមចូលក្រុងភ្នំពេញ កងទ័ពបដិវត្តិបាញ់តែកុដិលេខ៣៣ នៅវត្តលង្កា របស់ភិក្ខុធម្មបាល ខៀវ ជុំ ព្រោះព្រះអង្គត្រូវគេចាត់ទុកជាមនុស្សសំខាន់នៃរបបសាធារណរដ្ឋ ។ តែព្រះអង្គពុំបានគង់នៅទីនោះទេ ។ ពាក្យចចាមអារាមខ្លះបានថាព្រះអង្គត្រូវគេចាប់ខ្លួននៅមន្ទីរពេទ្យ កាល់ម៉ែត្ត ។ ខ្លះទៀតថាព្រះអង្គត្រូវពួកខ្មែរក្រហមតាមសម្លាប់នៅខេត្តកំពង់ឆ្នាំងក្នុងរយៈតែមួយឬពីរអាទិត្យបន្ទាប់គេកាន់កាប់ក្រុងភ្នំពេញ ៕

ចប់

Websites: WatKhemaraRatanaram.org or WatKhmers.org

# អារម្ភកថា

សត្វាកើតមកប្រាថ្នាក្តីសុខ , គេចដោះអំពីក្តីទុក្ខ , តែគេមិនសូវបានជួប មិនសូវបានរួច តាមសេចក្តីត្រូវការនិងមិនត្រូវការរបស់គេឡើយ ។ ដូចនេះ ព្រោះអ្វី? ព្រោះក្តីសុខកើតមកអំពីហេតុគឺធ្វើបុណ្យ , ក្តីទុក្ខកើតមកអំពីហេតុគឺធ្វើបាប ។ ជាមួយគ្នានេះទៀត , ក្តីសុខកើតពីគំនិតសន្តោស ក្តីទុក្ខកើតពីគំនិតល្មោភ ។ បើស្តីតាមសច្ចធម៌ , ក្តីសុខជាសម្មតិសច្ចៈ គឺមានឡើងដោយសន្មត់ , ក្តីទុក្ខជាសភាវសច្ចៈ មានប្រចាំលោកជានិច្ចនិរន្តរ៍ ។ ពោលគឺ សកលសត្វមានសុទ្ធតែទុក្ខ គ្មានសុខឡើយ។ ភាសាថាសុខ គឺជាក្តីទុក្ខយ៉ាងស្រាល , យ៉ាងខ្សោយ , ល្មមអត់បានធន់បានប៉ុននោះ ។ ព្រះអរហន្តទាំងឡាយមានព្រះពុទ្ធបរមគ្រូជាដើម ក្នុងពេលជួបគ្នាម្តងៗ លោកពុំដែលបានធ្វើសំនួរដល់គ្នានិងគ្នា ដោយប្រើភាសាថា " ម៉េចអ្នកឯងរស់នៅសព្វថ្ងៃ សុខសប្បាយទេឬ?" ផ្ទុយទៅវិញ , លោកអ្នកធ្វើសំនួរតែងប្រកាន់យកភាសាថា " ម៉េចសព្វថ្ងៃនេះ ល្មមទ្រាំរស់នៅបានឬទេ ?" ចំណែកលោកអ្នកឲ្យចម្លើយ តែងប្រកាន់យកភាសាថា "ល្មមប្រព្រឹត្តទៅបានដែរ" សំនួរចម្លើយនេះ បញ្ជាក់ឲ្យយើងឃើញថា សកលសត្វមានតែទុក្ខគ្មានសុខទេ។

កាលណាយើងគយគន់មើលដំណើរប្រព្រឹត្តទៅនៃជីវិតប្រចាំថ្ងៃរបស់យើងក្នុងមួយថ្ងៃៗយើងនឹងឃើញថា ខ្លួនយើងម្នាក់ៗបានជួបនឹងសេចក្តីពេញចិត្តខ្លះ មិនពេញចិត្តខ្លះ រីករាយខ្លះ ថ្នាំងថ្នាក់ខ្លះ ។ល។ យើងចូលចិត្តរបស់ល្អ មិនចូលចិត្តរបស់អាក្រក់ ,



Websites: WatKhemaraRatanaram.org or WatKhmers.org

តែយើងមិនដឹងថា ធ្វើយ៉ាងណាបានជួបនឹងរបស់ល្អ, ធ្វើយ៉ាងណាបានមិនជួបនឹងរបស់អាក្រក់ឡើយ ។

តែអ្នកដែលបានសិក្សាធម្មជាតិរបស់ជីវិត, គេអាចសង្កេតឃើញមនោសញ្ចេតនានៃជីវិត ដែលកើតរលត់ក្នុងចិត្តរបស់គេបានដោយអាស្រ័យធម្មៈជាគោលការនៃពុទ្ធសាសនា ឬសាសនាទាំងឡាយដទៃ គឺដឹងថា ខ្លួនគេកំពុងវង្វេងភាន់ច្រឡំ ឬស្រវឹងញៀនក្នុងចំណាញ់នៃរសក្នុងកាមលោក បានដល់សេចក្តីសប្បាយ ដែលកើតអំពីរូប សម្លេង ក្លិន រស ផ្សព្វ ។ល។ សុទ្ធសឹងជាធាតុបង្កបង្កើតនូវសេចក្តីពេញចិត្ត និងមិនពេញចិត្តជានិច្ចកាល ។

ខ្ពស់ជាងនេះទៀត, កាលណាគេបានសិក្សាធម្មជាតិរបស់ជីវិត ឲ្យបានច្រើន, បានជ្រៅទៅទៀត គេនឹងឃើញថា សូម្បីតែសេចក្តីស្រឡាញ់ពេញចិត្ត ក៏វាជាធាតុសម្រាប់តែផ្តល់អោយខ្លួន នូវទារុណកម្ម ប៉ុនគ្នានឹងសេចក្តីមិនស្រឡាញ់ពេញចិត្តហ្នឹងដែរ ។ ក្នុងន័យថា នៅស្ងៀមៗមិនកើត ឧស្សាហ៍ទៅស្អប់វា ទៅស្រឡាញ់វា ហើយមិនត្រឹមតែខំប្រឹងស្អប់ស្រឡាញ់ប៉ុននឹងទេ, បន្ថែមលើនេះ គឺខំប្រឹងព្យាយាមថែរក្សាវា យ៉ាងក្ងេចនឿយហត់ ដើម្បីមិនអោយវាបាត់បង់ទៅវិញទៀតផង ។

មនុស្សខ្លះមានគំនិតប្រកបដោយពន្លឺ មើលឃើញទុក្ខទោសនៅក្នុងសំអប់និងសម្ងាញ់ ហើយមិនចង់រស់នៅជាទាសភាពនៃធាតុទាំងពីរ, ចង់រើបំរះចាកទាសភាពនៅក្នុងក្របខ័ណ្ឌស្វែងរកធម៌ល្អប្រសើរដែរ, តែរកមិនឃើញព្រោះគេអនុវត្តសង្វែងមិនស្របនឹង



Websites: WatKhemaraRatanaram.org or WatKhmers.org

ពោធិបក្ខិយធម៌ ឬសង្វែងនៅក្រោមការក្បៀបសង្កត់នៃឧបាទាន គឺសង្វែងប្រាសចាកការលះកាត់ (ឧបាទាន) ។ សង្វែងបែបនេះ, មិនត្រឹមតែមិនផ្តល់អោយខ្លួន នូវគុណធម៌ល្អវិសេស តាមដែលមានចែងក្នុងទ្រឹស្តីនៃមជ្ឈិមាបដិបទា ឬអដ្ឋង្គិកមគ្គប៉ុននឹងទេ ។ ព្រមគ្នានេះ វាធ្វើអោយចិត្តមនុស្សយើង ធ្លាក់ចុះក្នុងរណ្តៅឧបាទាន កាន់តែធ្ងន់ឡើងៗ ជ្រៅទៅៗ ។ តែទោះជាយ៉ាងណាក្តី បើគេអនុវត្តព្រមគ្នាទាំងទំរើលះកាត់នុយឧបាទាន ទាំងទំរើស្វែងរកអរិយមគ្គនោះ គេមុខជាបានដល់ត្រើយរបស់ទុក្ខ ក្នុងពេលណាមួយមិនខានឡើយ ។ គឺមិនយូរមិនឆាប់, គេនឹងបានឆ្លងចាកអន្លង់ទុក្ខ ចូលទៅរស់ក្នុងត្រើយគ្មានទុក្ខ, គ្មានចំណង ។ល។ យ៉ាងពិតប្រាកដដូចក្តីប្រាថ្នារបស់គេ ។ ក្នុងន័យថា សត្តា មិនថារូបណាជារូបណាទេ, កាលណាខំប្រឹងស្តាបនាសង្វែងនៃអរិយមគ្គ, ខំប្រឹងកាត់ផ្តាច់នូវចំណងនៃកិលេសារឿយៗយូរៗទៅ គេនឹងបានដល់នូវភាពស្ងាប់សូន្យនៃឧបាទាន ហើយបានរស់នៅក្នុងភាវៈប្រសើរកំពូល ឬ ភាវៈប្រកបដោយអាថ៌កំបាំង ដែលលោកហៅថា" និព្វាន "ហ្នឹងឯង ។

ដូចនេះការប្រតិបត្តិធម៌ដើម្បីនិព្វាន ទើបជាការចាំបាច់សម្រាប់មនុស្សដែលប្រាថ្នាឆ្លងអន្លង់ទុក្ខ ចូលទៅកាន់ត្រើយគ្មានទុក្ខ ។ ពោលដោយខ្លីគឺ: មានតែនិព្វានបដិបទានមួយទេ, ដែលអាចបញ្ចប់ទុក្ខ, បញ្ចប់ចំបាំង, បញ្ចប់កំដៅ ។ល។ របស់ជីវិតសត្តាបាន ។ ចំណែកខាងបដិបទាទាំងឡាយដទៃ មានមគ្គបដិបទាជាដើម មិនអាចនិងបញ្ចប់ជាតុសត្រូវ និងជីវិតរបស់សកលសត្វបានឡើយ



Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រោះបដិបទាទាំងអស់នេះ មួយណាក៏ដូចជាមួយណាដែរ សុទ្ធតែបានស្ថិតនៅក្នុងអន្ទង់នៃអវិជ្ជា និងមាត់ដង្កាប់នៃឧបាទានា ។ល។ ដើម្បីពង្រឹង និងពង្រីកជំហរនិព្វានបដិបទា គេត្រូវសិក្សាអំពីនិព្វានបណ្ដុះគំនិតនិព្វាន ។ល។ គ្រប់ៗអាត្មា ។ នេះគឺជាគំនិតអ្នកសរសេររឿង និព្វាននៅឯណា ? ។

ក្នុងទីបំផុតនេះ អ្នកសរសេរសូមជូនដល់មិត្តរួមជាតិរួមលោក នូវគំនិតសិក្សា , គំនិតវិភាគ អំពីនិព្វាន ។ ជាមួយគ្នានេះ , សូមសកលមិត្ត បានរស់នៅក្នុងភាពស្ងប់ , ភាពត្រជាក់ , ភាពបងប្អូន ។ល។ គ្រប់ទិវារាត្រីកាល ដោយគ្មានទីបំផុត ចាប់តាំងពីសតវត្សនេះតទៅ ដោយសំនូមយ៉ាងបរិសុទ្ធរបស់អ្នកសរសេរនៅក្នុងក្របខ័ណ្ឌនៃព្រហ្មវិហារធម៌ ដែលប្រកាសដោយព្រះសមណគោត្តមបរមសាស្ដាចារ្យ ជាប្រទីបនៃសកលសត្វ ក្នុងសកលលោក ។

ភិក្ខុធម្មបាល ខៀវ ជុំ

ភ្នំពេញ វត្តលង្កា
ថ្ងៃទី ១៥ ខែ វិច្ឆិកា ១៩៧៣



Websites: WatKhemaraRatanaram.org or WatKhmers.org

# បញ្ហានៃនិព្វាន

**និព្វាន** មិនមែនជាប្រទេស, គេហដ្ឋាន, ប្រាសាទវិមានឬពិភពលោកជាលំនៅរបស់ព្រះអាទិទេព សឹងពោរពេញទៅដោយក្តីសុខយ៉ាងនិរន្តរ៍ ទំនាក់ទំនងដូចក្តីសុបិនក្តីស្រម័យ ដែលធ្លាប់មានក្នុងព្រលឹងរបស់មនុស្សាឡើយ ។

**និព្វាន** មិនបានមានន័យថា ជាភាពរួចផុតស្រឡះរបស់ខ្លួននៃមនុស្សម្នាក់ៗ អំពីលោកនេះ ទៅកាន់លោកដូចនេះទៀត និងមិនមែនជាភារៈនៃភាពមានខ្លួនប្រាណដូចទំរើគួសដៅដែលធ្លាប់មានលើគំនិតមនុស្ស ជាយូរមកហើយទេ ។

តែ " **និព្វាន** " លោកបានឲ្យន័យទៅលើភាពរលត់យ៉ាងកំពូល គឺសូន្យកំដៅ សូន្យដំនុត, ភាពចាក់ដោតមុតជល់, ភាពព័ទ្ធវិតរួត ដែលធ្លាប់មាននៅក្នុងចិត្តមនុស្សគឺកាត់ផ្តាច់ដោយផុតស្រឡះនូវដើមហេតុនៃកំណើតយ៉ាងដាច់ខាត, យ៉ាងអស់ដើងតែម្តង ។ ភាពដូចនេះ មាននៅជាធម្មតា ជាអនន្តកាល ហើយមាននៅគ្រប់ទីកន្លែងគ្រប់ពេលវេលា ។ ភាពនេះបានកើតប្រាកដជាក់ស្តែងដល់ចិត្តមនុស្សជានិច្ច ក្នុងពេលណាវិញ្ញាណរបស់គេប្រាសចាកកិលេស ។ ដូចនេះទើបលោកពោលថា និព្វានមានភាពតាំងនៅជានិរន្តរ៍, មាននៅគ្រប់ទី គ្រប់កន្លែង គ្រប់កាលវេលាយ៉ាងស្ថាពរគ្មានដាច់គ្មានបាត់សោះឡើយ ។ និព្វាននៅជិត, នៅជាប់ជាមួយនឹងខ្លួនយើង ក្នុងជីវិតអន្ទោលនេះឯង, តែយើងចូលមិនទាន់ដល់, មើលមិនទាន់ឃើញ



Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រោះចិត្តរបស់យើងមានកិលេស សឹងលោកហៅថា " សំបក " ជាគ្រឿងវេចខ្ចប់នៅឡើយ ។

## ការសើរើសង្កេតមើលនិព្វានជាថ្មីទៀត

កាលណាយើងសង្កេតពិចារណាមើលនិព្វាន ម្តងទៀតយើងនឹងឃើញថា កិលេសនិងសេចក្តីទុក្ខ មិនអាចនឹងមាននៅក្នុងសភាវៈនៃនិព្វានភាពបានទេ ព្រោះនិព្វាននឹងនៅជានិព្វានរហូតអនន្តកាល គ្មានទៅជាអ្វីដទៃឡើយ ។ ដូចនេះ ទើបមានពំនោលថា " និព្វានមិនមែនជាទីតាំង , មិនមែនជាទីអាស្រ័យនៅនៃកិលេស , នៃសេចក្តីទុក្ខ , តែជាធាតុ ជាទីមានភាពរលត់យ៉ាងកំពូល នៃភ្លើងកិលេស និងភ្លើងទុក្ខហ្នឹងតែម្តង ។

## និព្វានមើលក្នុងផ្លូវមួយទៀត

កាលណាចិត្តរបស់មនុស្សយើងបានពាក់កែរយឹត គឺបញ្ញា , យើងនឹងមើលឃើញសភាវៈនៃនិព្វានភាព យ៉ាងច្បាស់បន្តិចម្តងៗ ហើយយើងមុខជានឹងចាប់យកនូវនិព្វានភាពនោះជាអារម្មណ៍ ។ ជាមួយគ្នានេះ , ចិត្តរបស់យើងនឹងមានសេចក្តីតក់ស្លុតញាប់ញ័រស្រៀវខ្លាច ចំពោះសេចក្តីវង្វេងភាន់ច្រឡំ ដែលខ្លួនយើងធ្លាប់មាន ក្នុងកាលមុនយូរមកហើយ ដោយអាស្រ័យធម៌ជាន់ខ្ពស់ ដែលយើងបានចំរើននោះ ។ កិលេសក្នុងខន្ធសន្តានរបស់យើង ក៏ចាប់ផ្តើមរើងហួត



Websites: WatKhemaraRatanaram.org or WatKhmers.org

ទៅបន្តិចម្តងៗ, សេចក្តីទុក្ខប្រចាំខន្ធរបស់យើងក៏រសាត់រលាយទៅជាមួយនឹងរបើងនៃកិលេសរឿយៗដែរ ។ ដូចនេះហើយ, ទើបលោកពោលថា "និព្វានជាធម៌កំពូល" ជាគ្រឿងរំលត់យ៉ាងអស់ដើងនូវភ្លើងកិលេស និងភ្លើងទុក្ខទាំងឡាយ ដែលមាននៅក្នុងសន្តានរបស់សត្វ ។

## សេចក្តីសរុបដែលយើងត្រូវប្រកាន់យក

**និព្វាន** គឺជាសភាពនៃសេចក្តីរលត់យ៉ាងកំពូលនូវអ្វីៗទាំងអស់ដែលបង្កើតឡើងដោយកិលេស មានជាអាទ៍កំដៅ, ចំហេះ, ដំនុត, ចំនាក់, ដំនល់, បំនុក ។ ព្រមគ្នានេះទៀត ចំណងនៃកិលេសគឺសំយោជន៍ ដែលចងរឹតរួតវិញ្ញាណរបស់មនុស្ស ក៏ត្រូវបានដាច់ជ្រុះធ្លាក់ចាកសន្តានមនុស្ស ក្នុងពេលហ្នឹងដែរ ។ កិរិយាដែលអ្វីៗទាំងអស់, មានកំដៅជាដើម, បានរលត់អស់ទៅ គឺកិរិយាដែលចិត្តបានលុះដល់ភាពអស់កិលេស ឬ លុះដល់និព្វាន ដែលលោកហៅថា "ការនិព្វាន" ។ ការនិព្វានរបស់មនុស្សយើងដោយពិតប្រាកដនោះគឺនៅត្រង់ការដែលចិត្តរបស់មនុស្សយើងចូលទៅកាន់ភាវៈនៃភាពគ្មានកំដៅ, គ្មានចំហេះ, គ្មានដំនុត, គ្មានចំនាក់, គ្មានចំណង ។ល។ យ៉ាងដាច់ខាតយ៉ាងអស់ដើង ។

ភាវៈនៃនិព្វាន និងទំរើនៃនិព្វាន ឬការនិព្វាន មានភាពប្រាកដជាក់លាក់ឡើងក្នុងលោកជាគ្រាដំបូង ដោយអាស្រ័យ



Websites: WatKhemaraRatanaram.org or WatKhmers.org

ប្រាជ្ញាញាណរបស់ព្រះសមណគោត្តមបរមគ្រូព្រះអង្គបានចូលដល់ភាពរលត់ជាកំពូលនេះមុនសកលសត្វ ហើយព្រះអង្គជាមនុស្សទី ១ របស់ពិភពលោក ក្នុងទំរើស្រាវជ្រាវរកឃើញ នូវអ្វីដែលគេហៅថាទីបំផុតនៃលោក។ កំណើតរបស់ព្រះអង្គ ក៏មិនមែនជាអ្វីដ៏ទៃ ក្រៅពីការប្រសូតិ, ការត្រាស់ដឹង និងការបរិនិព្វាន ទាំងបីនោះឡើយ។ ដូចនេះ, ការប្រសូតិ, ការត្រាស់ដឹង និងការបរិនិព្វាន ទើបជារបស់មានឈ្មោះរួមគ្នាតែមួយ ដែលគេហៅថា " ប្រទីបសកលលោក "។ ប្រទីបសកលលោកបានមានជ័យជំនះលើមារទាំង៥គឺៈ កិលេសមារ, ខន្ធមារ, អភិសង្ខារមារ, ទេវបុត្តមារ, មច្ចុមារ ដែលលោកាមិនធ្លាប់ប្រយុទ្ធឈ្នះ ក្នុងអតីតកាល។ អាស្រ័យហេតុនេះទើបសកលលោកនាំគ្នាប្រកាន់យកហេតុការណ៍ទាំងបីយ៉ាងនេះ ថាជាហេតុការណ៍កើតមានឡើងក្នុងថ្ងៃតែមួយគឺ **ថ្ងៃវិសាខបូជា**។

**និព្វាន** ប្រែថារំលត់រំលាយយ៉ាងកំពូលនូវភាពក្តៅក្រហាយស្ដាបនាឲ្យសត្តានៅភាពត្រជាក់ត្រជុំក្សេមក្សាន្ត។ អ្វីជារបស់មានកំដៅ? ជីវិតជារបស់មានកំដៅ។ អ្វីជាជីវិត? ភ្នែក, ត្រចៀក, ច្រមុះ, អណ្តាត, កាយ, ចិត្ត, រូប, សម្លេង, ក្លិន, រស, ផោដ្ឋព្វៈ ធម្មារម្មណ៍ និង វេទនាទាំងឡាយ ដែលកើតឡើងដោយអាស្រ័យភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ដែលជាតួជីវិត ជារបស់ក្តៅ។ ក្តៅព្រោះអ្វី? ព្រោះភ្លើងកិលេសគឺៈ រាគៈ ទោសៈ មោហៈ។ ភាពត្រជាក់ជាកំពូលនៃរបស់ទាំងឡាយនេះ កើតមានឡើងព្រោះមិនបានត្រូវភ្លើងគឺៈ ទោសៈ មោហៈ ដុតបង្កាត់ឱ្យក្តៅនេះឯងគឺ **និព្វាន**។



Websites: WatKhemaraRatanaram.org or WatKhmers.org

ដូចនេះ**និព្វាន**មិនមែនជារបស់ដទៃឡើយ គឺជាភាពត្រជាក់ត្រជុំ ក្សេមក្សាន្តយ៉ាងកំពូលរបស់ជីវិតទាំងឡាយហ្នឹងឯង ។

សព្វថ្ងៃនេះ , ទោះណាជាគ្មានអ្នកណាប្រាប់ ក៏យើងដឹងបាន ថា សត្វលោកកំពុងរស់នៅក្នុងកំដៅ ហើយកំដៅនេះមានកំនើនជាង មុន ១ ជា ៥ ។ នេះក៏គ្មានព្រោះអ្វីដទៃទេ គឺព្រោះតែភ្លើងរាគៈ មោហៈ ទោសៈ ក្នុងវិញ្ញាណសត្វលោក ចេះតែមានចំហេះខ្លាំង ឡើងៗ ដោយហេតុដែលមនុស្សលោកកាន់តែមានសេចក្ដីឆ្លៀវឆ្លាត ខាងផ្លូវផ្គុំភ្លើងឲ្យមានកម្លាំងខ្លាំងឡើងៗតាមលំដាប់ ។ មនុស្សលោក រឹតតែគ្មានដឹង , គ្មានជំនឿ , គ្មានប្រកាន់យកថា ទំរើរលត់ភ្លើងរាគៈ ទោសៈ មោហៈ ជាចំណុចទិសដៅរបស់ជីវិតនៃបុគ្គលស្វែងរកទិស ដៅនៃសន្តិភាព និងជាទំរើលប់បំបាត់ នូវគំនិតស្វែងរកសេចក្ដី សប្បាយលើបញ្ចកាមគុណ ដែលជាគ្រឿងពង្រីកភ្នក់ភ្លើងឲ្យកាន់តែ ធំ ដោយប្រើគំនិតបញ្ឆោះ ច្រើនជាងគំនិតពន្លត់ ។ សកលលោកបាន ក្លាយទៅជារបស់មានចំហេះ មានកំដៅ ទាំងមនុស្ស ទាំងសត្វ ទាំង សកលធាតុ ។ ព្រោះអ្វី? ព្រោះមនុស្សក្នុងពិភពលោកនាំគ្នាស្វាប អង្អែលបញ្ចកាមគុណ , នាំគ្នាបំរើសេចក្ដីសប្បាយបោកប្រាស់ប្រកប ដោយចិត្ត សឹងពោរពេញទៅដោយរាគៈ ទោសៈ មោហៈ លើសជាង សម័យមុន ១ ជា ១០ ។ ដរាបណាសត្វលោក នៅតែមានគំនិតយល់ ខុស , នៅតែគ្មានសម្មាទិដ្ឋិដូចនេះ ភាពត្រជាក់ត្រជុំនៃនិព្វាន មិន អាចកើតមានបានឡើយ ។ ដើម្បីសម្រេចនិព្វាន ឬផ្ដល់ឲ្យជីវិតនូវ



Websites: WatKhemaraRatanaram.org or WatKhmers.org

សន្តិភាពជាស្ថាពរ, មុខងាររបស់មនុស្ស គឺត្រូវរួមកម្លាំងព្រួតដៃគ្នាជួយលត់ភ្លើងកិលេស ឲ្យអស់បន្តិចម្តងៗ តាមលំដាប់នៃកាលវេលា ។

ក្នុងបច្ចុប្បន្ននេះ, មនុស្សបានតែនាំគ្នាជ្រួលច្របល់ពពាក់ពពូន ជំពាក់ជំពិនលើទំរើដុតបំផ្លាញខ្លួនឯង គឺនាំគ្នាថ្ងូរ, នាំគ្នាជូរចត់ក្នុងជីវិតរៀងៗខ្លួន, តែគ្មានគិតគ្មានទឹកគ្មានសុបិន គ្មានស្រមៃដល់និព្វានឡើយ ។ ក្នុងន័យថា សកលសត្វ គ្មានបានទទួលប្រយោជន៍អ្វីអំពីនិព្វាន សូម្បីបន្តិចបន្តួចឡើយ ទោះណាជានិព្វានមាននៅគ្រប់ទីកន្លែង គ្រប់ពេលវេលាក៏ដោយ ។ ដូចនេះព្រោះអ្វី? ព្រោះសកលសត្វគ្មានស្មារតីភ្ញាក់រលឹក គ្មានមនសិការស្តារទុក្ខ, គ្មានសម្បជញ្ញសន្តិភាព ។

## សូមនាំគ្នាពិនិត្យមើលជ្រុងមួយទៀត

**និព្វាន** ប្រែថា ប្រាសចាកគ្រឿងមុត គ្រឿងជល់ គ្រឿងចាក់ដោត ។

អ្វីជាគ្រឿងមុត ជល់ ចាក់ដោត? លោកឬជីវិតដែលយើងស្គាល់រាល់គ្នាហ្នឹងឯង ។ បុគ្គលដែលមានគំហើញមិនត្រូវ ឬមានគំនិតយល់ខុស ដែលយើងធ្លាប់ហៅថា " មិច្ឆាទិដ្ឋិ " គេមានផ្នត់គំនិតប្រកបដោយសេចក្តីស្រវឹង, មានគំហើញប្រកបដោយសេចក្តីញៀន, គេប្រាថ្នាលើកខ្លួនធ្វើជាម្ចាស់សកលលោក ។ ចំណង់គ្មានព្រំដែននេះ, មិនត្រឹមតែផ្តល់អោយ នូវសេចក្តីវិនាសចំពោះខ្លួនឯង



Websites: WatKhemaraRatanaram.org or WatKhmers.org

ប៉ុននឹងទេ, បន្ថែមលើនេះគឺផ្តល់គ្រោះថ្នាក់ដល់ជាតិ, ដល់បក្សពួករបស់ខ្លួនផង។ បុគ្គលពួកខ្លះទៀត, មើលឃើញលោកនៅក្នុងលក្ខណៈល្អប្រសើរ គួរនឹងប្រព្រឹត្តទៅតាមសេចក្តីប្រាថ្នារបស់ខ្លួន និងបក្សពួករបស់ខ្លួន។ គំហើញនេះបានផ្តល់ឲ្យពួកនេះ នូវគំនិតលោភលន់, នាំគ្នាអនុវត្តទំរើបែកពិភពលោកជាចំណិតៗ ចំណែកៗ ហើយពង្រឹងកម្លាំងពង្រីកអំណាច ក្នុងភូមិភាគមួយៗរៀងៗខ្លួន, លុះបានឱកាសក៏ចាប់អនុវត្តទំរើឈ្លានពាន វាយប្រហារបំផ្លិចបំផ្លាញគ្នាដោយប្រើគំនិត ជិះជាន់ផ្អែកលើពន្លឺវិទ្យាសាស្ត្រ នៅក្នុងក្របខ័ណ្ឌនៃវិញ្ញាណអកុសល ដែលខ្លួននឹងបក្សពួកសន្សំបានច្រើន គ្រប់គ្រាន់ល្មមនឹងដុតបញ្ឆេះរំលាយពិភពលោកអោយក្លាយជាផ្សេង ខ្ទេចជាផេះ ក្នុងរយៈពេលត្រឹមមួយវិនាទី ដើម្បីបំពេញចំណង់តណ្ហាកខ្វក់របស់ខ្លួន និងបក្សពួក។ ដទៃពីនេះទៀត, គំនិតរបស់មនុស្សម្នាក់ៗមានការប្រកាន់យករបស់ដែលមានភាពមិនទៀង ជាទុក្ខ ជាអនត្តាថាជាទៀង ជាសុខ ជាអត្តា។ កំណាន់ និងគំហើញនេះ នាំអោយគេចិញ្ចឹមសេចក្តីសង្ឃឹម, ខំពង្រីកសេចក្តីសប្បាយ, ខំពង្រឹងគំនិតយល់ខុសបន្ថែមឡើងទៀត គ្មានចប់គ្មានអស់ហើយឡើយ។ លទ្ធផលរបស់គេក្នុងរឿងនេះ គឺសំនើចលាយទំនួញ សំអប់លាយសំឡាញ់សម្ងួតលាយកំណាច។ល។ ផ្លាស់ប្តូរគ្នាទៅវិញទៅមក នៅក្នុងក្របខ័ណ្ឌនៃការដុតបំផ្លាញខ្លួនឯង ដោយវិធីផ្សេងៗយ៉ាងមុខគួរអោយសង្វេគខ្ទោចផ្សាដោយគ្មានដឹងខ្លួនឡើយ។ គំហើញកំឡោរបស់សត្វា បានបង្កើតឲ្យគេនូវគំនិតថា របស់ផ្សេងៗដែលជាគ្រឿង


Websites: WatKhemaraRatanaram.org or WatKhmers.org

បំរើសេចក្ដីសប្បាយរបស់ខ្លួន ឬដែលខ្លួនយកមកប្រើ ដើម្បីបំរើសេចក្ដីសប្បាយនោះ គឺជាគំនិតត្រូវ, តែគំនិតសច្ចធម៌មានមកថា មនុស្សទាំងឡាយទេដែលបានយកខ្លួនទៅបំរើរបស់ទាំងអស់នោះ នៅក្នុងក្របខ័ណ្ឌនៃការបំរើតណ្ហារបស់ខ្លួនៗ ចំនាក់, ជំនល់, ជំនោត ... ទាំងឡាយមាននៅពោរពេញក្នុងជីវិតសត្វាដែលកំពុងត្រាច់រង្គត់ ក្នុងវាលវដ្ដសង្សារ គ្មានវត្ថុសក្តិសិទ្ធិខ្លាំងពូកែណា អាចដកគ្រឿងចាក់ គ្រឿងដោត គ្រឿងជល់ ... នេះបានឡើយ ប្រសិនបើប្រជាសត្វ នៅតែមិនយល់ មិនដឹង មិនឮ មិនចូលចិត្តសច្ចធម៌ តាមបែបដែលព្រះគោត្តមបរមគ្រូបានរកឃើញ, បានស្វែងជួប ។ ដើម្បីដកពិសសរ ពោលគឺកិលេសទាំងឡាយ ដែលជាគ្រឿងមុតកប់, គ្រឿងចាក់ដោតលើវិញ្ញាណសកលសត្តានោះ គេមិនឃើញមានគ្រឿងដក គ្រឿងជីកណាដទៃ ក្រៅពីសទ្ធម្មដែលប្រកាសដោយព្រះសម្មាសម្ពុទ្ធឡើយ ។

ក្នុងពេលបច្ចុប្បន្ននេះ, សត្វលោកកំពុងមានព្រលឹងឈ្ងក់វក់វីជ្រួលច្របល់តែលើជំនោតគ្រាប់សរ គ្រាប់ព្រួញនៃកិលេសតណ្ហាឧបាទាន ដែលបានមុតចូលទៅក្នុងចិត្តរបស់ខ្លួន ។ ដោយអំណាចពិសសរនេះ គេបានទទួលការពើតចាប់ចុកសៀតយ៉ាងខ្លាំងក្លា, តែគេមិនដឹងធ្វើយ៉ាងណា អោយពិសសរនេះបានដកចេញពីវិញ្ញាណរបស់គេឡើយ ។ គេទាំងឡាយស្អប់ខ្ពើមទុក្ខព្រួយណាស់, ចង់បំបាត់ទុក្ខណាស់, តែគេមានកង្វះខាងមធ្យោបាយសម្រាប់អនុវត្ត ។ ពេលវេលាចេះតែដើរទៅរឿយៗគ្មានឈប់ ដំបៅលើវិញ្ញាណរបស់គេ ចេះ



Websites: WatKhemaraRatanaram.org or WatKhmers.org

តែបញ្ចេញកំឡាំងបៀតបៀនចាក់រុកខ្លួនគេជានិច្ច, សេចក្តីឈឺចាប់របស់គេ បានក្លាយជាទម្លាប់, ជាលំញៀន ព្រោះតាំងពីកើតមកដំនោតសរនេះបានមុតចូលក្នុងខ្លួនរបស់គេគ្រប់ៗអត្មា គ្មាននរណាម្នាក់ចៀសវាងគេចដោះបាន ។ ដូចនេះឃើញថា សកលសត្វគ្មានបានទទួលផលប្រយោជន៍អ្វីអំពីនិព្វាន ដែលជាធាតុមាននៅគ្រប់ទីគ្រប់កន្លែងគ្រប់វេលាសូម្បីបន្តិចបន្តួចឡើយ ។ ព្រោះអ្វី? ព្រោះគ្មានស្គាល់ព្រះសទ្ធម្ម, គ្មានយកចិត្តទុកដាក់លើន័យរបស់ពាក្យថា " ***វិសាខបូជា*** " ហ្នឹងឯង ។

## មេត្តាមើលជ្រុងមួយទៀត

**និព្វាន** ប្រែថា ប្រាសចាកបំណង, ប្រាសចាកប្រដាប់រុំព័ទ្ធ, ប្រាសចាកប្រដាប់វេញគ្រង ។

អ្វីជាគ្រឿងចង គ្រឿងរុំព័ទ្ធ? សេចក្តីចូលចិត្តខុសក្នុងបញ្ហាជីវិត ព្រោះអាស្រ័យកំឡៅដែលមាននៅក្នុងគ្រប់វិស័យគ្រប់ជ្រុង ជាគ្រឿងចង គ្រឿងរុំព័ទ្ធ ។ សេចក្តីលោភក្តី សម្ងាញ់ក្តី សំអប់ក្តី កំហឹងក្តី ចំនែនក្តី គំនុំក្តី កំឡាចក្តី កំណាន់ក្តី ។ល។ ទាំងអស់នេះសុទ្ធតែជាគ្រឿងចងព័ទ្ធវិតរួតចិត្ត, ជាគ្រឿងខ្ទប់វេចវិញ្ញាណរបស់សត្វាមិនឲ្យមើលឃើញផ្លូវដើរ និងមធ្យោបាយដោះស្រាយ ។ ជីវិតរស់នៅក្នុងគុកកិលេសបែបនេះ, កាលណាសត្វគុកទទួលស្គាល់នូវសេចក្តីសុខឬរបស់ដែលខ្លួនចូលចិត្ត, ខ្លួនស្រឡាញ់ថាជារបស់ខ្លួន, ខ្លួនក៏ត្រូវ



Websites: WatKhemaraRatanaram.org or WatKhmers.org

ទទួលស្គាល់ទុក្ខ ឬរបស់ដែលខ្លួនមិនចូលចិត្តថាជារបស់ខ្លួនដែរ ទោះណាជាខ្លួនគ្មានចង់ គ្មានប្រាថ្នាក៏ដោយ ។ ដូចនេះព្រោះអ្វី? ព្រោះជៀសមិនផុត គេចមិនរួច មិនស្គាល់មិនបានហ្នឹងតែម្តង ។ ភាវៈនៃការប្រាសចាកចំណង់គ្រប់បែបយ៉ាង រមែងបានដល់នូវភាវៈគ្មានកំដៅ, គ្មានចំណាក់ គឺគ្មានគ្រឿងចាក់រុកដោត ក្រងចិត្ត ។ ក្នុងន័យថា ជាសះស្បើយអស់ជំហឺចិត្ត ព្រោះអស់កិលេសតណ្ហា ជាគ្រឿងបញ្ឆេះអោយកើតកំដៅ ពោលគឺសេចក្តីទុក្ខ ដែលលោកពោលថាបានសំរេចនិព្វានហ្នឹងឯង ។

លោកយើងសម័យនេះ កំពុងអូសទាញគ្នាចូលទៅកាន់ភាពស្មុគស្មាញ ខាងការនយោបាយ, ការសេដ្ឋកិច្ច, ការសង្គ្រាម និងការទាំងឡាយដទៃទៀត កាន់តែធំឡើងៗជ្រៅទៅៗ ។ នេះជាតួយ៉ាងមួយបញ្ជាក់ឲ្យឃើញលក្ខណចិត្ត ដែលត្រូវកិលេសទូទៅគ្របសង្កត់ និងផលវិបាកដែលកើតឡើង អំពីចំណងនៃអវិជ្ជាតណ្ហាដោយចំពោះ ។ តែទោះជាយ៉ាងណាក៏ដោយសេចក្តីពិតបានប្រាប់យើងថា

កាលណាធូលីដីចូលភ្នែកយើងហើយ យើងត្រូវធ្មេច យើងមើលអ្វីគ្មានឃើញទេ, របស់ដែលបិតនៅជុំវិញខ្លួនយើង បានក្លាយជាឧបសគ្គដល់ទំរើការងាររបស់យើង គឺយើងត្រូវទទួលគ្រោះថ្នាក់ដោយធ្លាក់ជណ្តើរ ឬរណ្តៅក្បែរខាង ឬប៉ះទង្គិចនឹងវត្ថុអ្វីៗជាមិនខានប្រសិនបើគ្មានអ្នកនាំផ្លូវក្នុងពេលនោះ ។ នេះគឺជាលទ្ធផលនៃទំមេចព្រោះធូលីដីចូលភ្នែករូប ។ ចំណែកធូលីដីអវិជ្ជា ដែលចូលភ្នែកវិញ្ញាណ ក៏ជាហេតុធ្វើឲ្យដួងចិត្តដួងព្រលឹងរបស់យើង បាន



Websites: WatKhemaraRatanaram.org or WatKhmers.org

ទទួលគ្រោះថ្នាក់ដូចរូបដែរ តែយើងមើលមិនសូវស្គាល់, ស្គាល់ហើយយល់មិនសូវច្បាស់ ទើបយើងរកមធ្យោបាយយកធូលីដីអវិជ្ជាចេញពីភ្នែកវិញ្ញាណរបស់យើងមិនបាន ។ គឺដូចនេះហើយបានជាសកលសត្វពុំអាចលប់បំបាត់គំនិតល្មោភ, គំនិតសំអប់, គំនិតកំដៅដែលមាននៅក្នុងអាត្មាខ្លួន ។ ក្នុងរយៈកាលដែលជីវិតកំពុងអន្ទោលគំនិតអកុសលនេះ វាបានបង្កើតចម្បាំងឲ្យសកលសត្វ ដូចដែលយើងបានឃើញបានទទួលរងគ្រោះមកហើយ ។ វិញ្ញាណសត្វលោកក្នុងសតវត្សនេះ កំពុងត្រូវបានជាប់សំណាញ់មោហៈ, កំពុងត្រូវរស់នៅក្នុងគុកអវិជ្ជា ។ ឥទ្ធិពលនៃភាពងងឹតនេះ បានធ្វើអោយមនុស្សកើតគំនិតអកុសលកាន់តែច្រើនឡើងៗ ។ ដោយមានគំនិតកំឡៅជាហេតុ, ទើបទំរើអ្វីៗដែលសត្វលោកអនុវត្ត គេឃើញសុទ្ធតែជាទំរើយកឈ្នះអ្នកដទៃច្រើនជាងយកឈ្នះខ្លួនឯង ។ ក្នុងន័យថា មនុស្សាមិនព្រមប្រកាសសង្គ្រាម, មិនព្រមធ្វើសកម្មប្រយុទ្ធនឹងកិលេសតណ្ហារបស់ខ្លួន តែស្មគ្រប្រកាសសង្គ្រាម ធ្វើសកម្មប្រយុទ្ធជាមួយនឹងមនុស្សគ្នាឯង ដែលមានចិត្តលង់លិចក្នុងអន្ទង់អវិជ្ជា មានសេចក្តីទុក្ខព្រួយដូចគ្នាទៅវិញ ។ ដើម្បីសន្តិភាពនៃសកលជីវិត ពុទ្ធសាសនាបានអោយគំនិតថា សកលមនុស្សត្រូវឈប់លើកធ្វើចម្បាំងនឹងមនុស្សគ្នាឯង ហើយត្រឡប់មកធ្វើសង្គ្រាមនឹងកិលេសតណ្ហារបស់ខ្លួន នៅក្នុងក្របខ័ណ្ឌរំលាយសកលទុក្ខ ។ ពុទ្ធសាសនាបានធ្វើសេចក្តីបញ្ជាក់ថា មានតែទំរើនេះទេ, ដែលអាចធ្វើអោយសកលជីវិតបានទទួលសន្តិភាពជាស្ថាពរបាន ។



Websites: WatKhemaraRatanaram.org or WatKhmers.org

សព្វថ្ងៃនេះសកលជីវិត កំពុងឋិតនៅក្នុងភាពជំពាក់ជំពិន, ភាពស្មុគស្មាញទាំងខាងក្រៅទាំងខាងក្នុង , កំពុងរស់នៅក្នុងជម្ពោះ , កំពុងរស់នៅក្នុងសំណាញ់ ឬអន្ទាក់នៃមោហៈយ៉ាងធំធេង ដែលបង្កើតឡើងដោយធម្មជាតិឬមារ ។ ទទឹមគ្នានេះគេគ្មានដឹងថា ខ្លួនគេជាសត្វជាប់ទ្រុងជាប់អន្ទាក់មារឡើយ សត្វលោកគ្មានប្រាថ្នាដោះចិត្តចេញពីអន្ទាក់មារ , គ្មានឃើញប្រយោជន៍ ដែលកើតអំពីដំណោះនៃអន្ទាក់នេះ , ព្រោះគេគ្មានដឹងថា ខ្លួនគេរស់នៅក្នុងជំទាប់នៃអន្ទាក់ គ្មានដឹងថាជំទាប់នេះ បានផ្តល់អោយគេនូវសេចក្តីទុក្ខគ្រប់ប្រការឡើយ ។



Websites: WatKhemaraRatanaram.org or WatKhmers.org

## និព្វានជាចំនុចទិសដៅចុងក្រោយបង្អស់នៃជីវិត

និព្វាន មិនមែនជាធាតុចិត្ត មិនមែនជាធាតុចេតសិត ដែលកើតឡើងជាមួយនឹងចិត្ត ហើយអាស្រ័យចិត្ត មិនមែនជាធាតុមានរូបរាង ប្រកបដោយដុំដោយកង់ ក្នុងប្រភេទរូបធម៌, មិនមែនជាស្រុកជាទេស មិនមែនជាដួងផ្កាយ មិនមែនជាដុំពិភពលោកមួយៗ ។ ខ្ពស់ជាងនេះ, និព្វានមិនមែនជារបស់ដែលមានភាពកើតមក, មិនមែនជារបស់ដែលមានភាពរលត់ទៅ, មិនមែនជាភាពមានដំណើរទៅ, មិនមែនជាភាពមានដំណើរមក, មិនមែនជាភាពមានឧបត្តិ, មិនមែនជាភាពមានចុត្តិ ។ល។ តែនិព្វានជាសភាវៈនៃធម្មជាតិមួយបែប, ហើយជារបស់តែមួយគត់ ដែលគ្មានប្រភពនៃការប្តូចប្តើម កើតមានឡើងដូចរបស់ទាំងឡាយដទៃ ។ ប៉ុន្តែនិព្វានជារបស់មានហើយចេះតែ មាននៅរហូតជាអនន្តកាល, គ្មានចេះរលត់, គ្មានចេះសូន្យ, ព្រោះគ្មានពេលត្រូវរលត់, គ្មានពេលត្រូវផ្លាស់ប្តូរប្រែប្រួល ។

តាមធម្មតា វត្ថុទាំងឡាយដទៃ ក្រៅអំពីនិព្វាន, ដំបូងបំផុត, ត្រូវមានការប្តូចប្តើមចាប់កំណើត, បន្ទាប់មកត្រូវមានភាពទ្រុឌទ្រោម, ទីបំផុតត្រូវមានភាពរលត់រលាយជានិច្ច, ខុសគ្នាតែយូរឆាប់ប៉ុននោះ ។ ព្រោះអ្វី? ព្រោះរបស់ទាំងឡាយនេះ សុទ្ធតែត្រូវប្តូចប្តើមមានឡើងដោយអាស្រ័យកំណើត ។ នេះគឺជាច្បាប់របស់ធម្មជាតិ ដែលតែងតែមានការវិវត្តន៍ពីដំណាក់មួយទៅដំណាក់មួយទៀត គឺមានកើតមានទ្រុឌទ្រោម មានរលត់រលាយជាធម្មតា មិនថារបស់



Websites: WatKhemaraRatanaram.org or WatKhmers.org

ណាជារបស់ណាទេ សូម្បីតែវត្តមាននៃដួងអាទិត្យ ដែលវិទ្យាសាស្រ្ត បានប្រាប់ថា មាននៅក្នុងអាកាសធាតុអស់រយៈកាលយូរអង្វែង ណាស់មកហើយ គឺកើតមានឡើងមុនអ្វីៗទាំងអស់ក្នុងសកល ចក្រវាឡក៏គង់ចៀសវាងទីបំផុតមិនរួចពេលណាមួយ វត្តមាននៃដួង អាទិត្យនឹងក្លាយទៅជាអវត្តមានជាមិនខានឡើយ ។ ជាមួយគ្នានេះ ទៀត , ដី , ទឹក , ភ្លើង , ខ្យល់ , ជំនាក់[1] , កំដៅ ។ល។ ដែលយើងបាន ឃើញ , បានប្រើប្រាស , បានអាស្រ័យនៅសព្វថ្ងៃនេះ ក៏ពុំអាចគេច ដោះពីទីបំផុតបានឡើយ , ពេលណាមួយវត្តមាននៃសកលធាតុទាំង អស់នេះ នឹងក្លាយទៅជាអវត្តមានដូចៗគ្នា ។ ព្រោះអ្វី ? ព្រោះសកល វត្ថុសុទ្ធតែមានកំណើត , មានវត្តមានដោយអាស្រ័យរបស់ដទៃ ដែល យើងបានចេះចាំមកថា កំណើតមានបច្ច័យតុបតែង ។ សង្ខត កំណើត គឺជាប្រពៃណីនៃធម្មជាតិក្តី សង្ខតវត្តមានក្តី មួយណាក៏ដូច ជាមួយណា ទីបំផុតរបស់វា គឺរលត់រលាយហ្នឹងឯង ។

ចំណែករបស់ដែលយើងហៅថា " **និព្វាន** " មានន័យ មាន លក្ខណៈខុសពីរបស់ដទៃ គឺនិព្វានជាអសង្ខតវត្តមាន , មិនមាន កំណើត , មិនមានអាស្រ័យនឹងរបស់ដទៃ ។ ដោយហេតុថា និព្វាន មានឯងនៅក្នុងភាពនៃនិព្វានតែម្តង ទើបបានជាតុនេះមិនចេះរលត់ មិនចេះរលាយ ។ វត្តមាននៃនិព្វាន មាននៅរហូតអស់កាលជានិច្ច និរន្តរ៍ គ្មានទីបំផុតខាងដើមគឺគ្មានជាតិកំណើត , គ្មានទីបំផុតខាងចុង គឺគ្មានរលត់រលាយ ។ ហេតុនេះ និព្វាន ទើបមិនមែនជារបស់ដែល

---

[1] ជំនាក់ពាក្យនាមមកពីកិរិយាស័ព្ទថា"ជាក់"ដែលក្លាយមកជា"ត្រជាក់" ។



Websites: WatKhemaraRatanaram.org or WatKhmers.org

នរណាៗលើកមកនិយាយ ដោយសំអាងហេតុផលតាមគំហើញរបស់ខ្លួនថា និព្វានគឺជាអតីតកាល, អនាគតកាល, បច្ចុប្បន្នកាលបានឡើយ ។ ដូចនេះព្រោះអ្វី? ព្រោះភាពមាននៃនិព្វាននោះ មានលក្ខណៈខុសពីភាពមាននៃរបស់ទាំងឡាយដទៃយ៉ាងអតិបរមា គ្មានអ្នកណាម្នាក់អាចកំណត់ក្នុងពំនោលរបស់ខ្លួនបានឡើយ ។

**និព្វាន** មាននៅរហូតគ្មានទីបំផុត និងគ្មានកំណត់ដោយកប្បកាល គឺមាននៅជានិច្ចជាអនន្តកាល ។ របស់ដែលគួរលើកមកធ្វើជាគូនិងនិព្វាននោះ គឺពេលវេលា ។ ព្រោះអ្វី? ព្រោះពេលវេលាក៏គ្មានទីបំផុត, គ្មានទីចប់ដូចនិព្វានដែរ ។ តែកុំយកន័យថា ពេលមានទីបំផុតដូចជាពេលថ្ងៃចន្ទបានអស់ទៅ មានពេលថ្ងៃអង្គារចូលមកជំនួស ហើយក្នុងចន្លោះរវាងចន្ទនិងអង្គារ កំណត់ជាទីបំផុតនៃពេលឡើយ ។ គឺត្រូវយកន័យថា ពេលគ្មានទីបំផុត, គ្មានចុងចប់ទេ រីឯថ្ងៃ ខែ ឆ្នាំ ។ល។ ធាតុទាំងអស់នេះ បានត្រឹមជាខ្នាច់សម្រាប់រាប់ សម្រាប់កំណត់ពេលដែលកំពុងប្រព្រឹត្តទៅប៉ុននោះ ។

**និព្វាន** ជាធាតុបើកទ្វារចំហរ ចាំទទួលអ្នកត្រូវការជួប ត្រូវការទាក់ទងជានិច្ច និព្វានព្រមជួយព្រមប្រាស្រ័យទាក់ទងជាមួយនឹងចិត្តរបស់មនុស្សគ្រប់ៗអាត្មា, តែចិត្តធម្មតារបស់យើងមានសំបកច្រើនជាន់ ច្រើនស្រទាប់វេចខ្ចប់ពីខាងក្រៅ ពុំបានបើកឱកាសអោយនិព្វានចូលជួប ចូលទាក់ទងបាន ។ និព្វានទើបគ្មានភាពប្រាកដ នៅក្នុងចិត្តរបស់យើង, ចំណែកយើងវិញក៏មិនដឹងថា និព្វានមាននៅក្នុងទីណា, ទោះជានិព្វានមាននៅគ្រប់ទិសទី, មានភាពអាចជ្រាប



Websites: WatKhemaraRatanaram.org or WatKhmers.org

ចូលទៅក្នុងទិសទីទាំងឡាយបាន , មានភាពទូលំទូលាយពិសេស ពិសាលក្រៃលែងជាងអាកាស ដែលយើងចាំបានថា មានទូទៅ ពាសពេញសកលលោកនោះទៅទៀត ។ មនុស្សយើង កាលណាបើ មិនអាចកំណត់អំពីនិព្វានឬមិនអាចចូលជួបនិព្វានបាន ក៏នាំគ្នា បញ្ចប់គំនិតរបស់ខ្លួនថា និព្វានគ្មាននៅគ្រប់ទិសទីដូចពំនោល ទាំងឡាយឡើយ ។ ជាមួយគ្នានេះ , គេនាំគ្នាយល់ថា ពំនោល ទាំងឡាយដែលមានអំពីរឿងនិព្វាននោះ វាត្រឹមតែជាពំនោលលេង វោហារលេងសំនួរ ដើម្បីពិរោះត្រចៀកអ្នកល្ងង់ប៉ុននឹងទេ ។ អ្នកអាន សូមមេត្តាគិតថា មនុស្សមានភ្នែកខ្វាក់អំពីកំណើត រមែងមិនស្គាល់ ពន្លឺទាំងឡាយដែលមាននៅក្នុងលោកនេះទេ , ទោះជាពន្លឺនោះនៅ ជិតបង្កើយនឹងភ្នែករបស់ខ្លួនក៏ដោយ , យ៉ាងណាមិញ ។ បុគ្គលអ្នក ខ្វាក់ភ្នែកចិត្ត ដោយអវិជ្ជាបិទបាំងវេចខ្ចប់ ក៏មិនអាចស្គាល់និព្វាន , មិនអាចកំណត់និព្វានថា ដូចនេះដូចនោះបានយ៉ាងនោះដែរ ។ បុគ្គលអ្នកស្គាល់និព្វានឬចូលចិត្តនិព្វានបាន មានតែមួយពួកប៉ុន នោះ គឺពួកដែលបានបកសំបក ពោលគឺកិលេសចេញអំពីចិត្តរបស់ ខ្លួន , ជាពិសេសគឺជាប់ផ្ទាំងងងឹត គឺអវិជ្ជាចេញអោយអស់ពីវិញ្ញាណ របស់ខ្លួន , ធ្វើអោយវិញ្ញាណអស់កង្វាក់ , អស់ងងឹតហ្នឹងឯង ។

ជីវិតមនុស្សកើតចាកផ្ទៃម្តាយ រស់នៅលើដុំនៃពិភពលោក នេះ ខ្វាក់ភ្នែកក្នុងដូចគ្នាទាំងអស់ ទើបមិនដឹង, មិនស្គាល់រឿង និព្វាន ។ ក្រៃលែងជាងនេះ , មនុស្សដែលខ្វាក់ភ្នែកក្រៅមួយជាន់ ទៀត , គ្នាមិនត្រឹមតែគ្មានស្គាល់និព្វានប៉ុននឹងទេ , គឺគ្មានស្គាល់ពន្លឺ



Websites: WatKhemaraRatanaram.org or WatKhmers.org

គ្មានស្គាល់វត្ថុធាតុដែលជាគ្រឿងឧបសគ្គ ដល់ជីវិតរបស់គ្នាថែមទៀតផង ។ កង្វាក់ភ្នែកខាងក្រៅអំពីកំណើត ពេទ្យមិនអាចព្យាបាលអោយជាបានទេ, តែកង្វាក់ភ្នែកក្នុង (ភ្នែកបញ្ញា) ឬកង្វាក់ភ្នែកចំពោះនិព្វាន, ពេទ្យធម៌ព្យាបាលបានប្រសិនបើគេមានជំនឿ ។ បុគ្គលខ្វាក់ភ្នែកស្បែក តែភ្នែកចិត្តភ្លឺល្អ អ្នកប្រាជ្ញលោកថាមិនអភ័ពទេ ។ បើតាមទំនាក់ទំនងនេះ យើងអាចឃើញបានថា ពន្លឺនិព្វានចាំងចុះទៅដល់ទីដល់ទិសទាំងឡាយ ដែលពន្លឺរស្មីក្នុងពិភពលោកចាំងមិនដល់ ។ ដួងចិត្តរបស់មនុស្សកង្វាក់ភ្នែកស្បែក បានជួបឃើញនិព្វាន ដូចជនទាំងឡាយដទៃដែរ ប្រសិនបើគេមានបញ្ញាចក្ខុ ។ ក្នុងន័យថា សកលសត្វ ទោះណាស្បែកភ្នែកខ្វាក់ គេត្រូវតែមើលនិព្វានឃើញ ក្នុងពេលណាមួយមិនដាច់ក៏យូរស្រេចហើយតែបញ្ញា ដែលគេសន្សំបានច្រើនតិច ។

មនុស្សមានភ្នែកក្រៅភ្លឺល្អ មិនសូវបានដឹងថា ខ្លួនមានភ្នែកក្នុងប្រកបដោយកង្វាក់ទេ ។ ភ្នែកខាងក្រៅវាដណ្តើមយកពេលធ្វើការអស់រលីង, ភ្នែកខាងក្នុងដណ្តើមការមិនទាន់ ក៏ចាប់បណ្តោយទៅតាមភ្នែកខាងក្រៅទៅ ។ ដូចនេះ ទើបគេឃើញមនុស្សខ្វាក់ភ្នែកក្រៅ រៀនវិជ្ជាអ្វីៗឆាប់ចេះឆាប់ចាំជាងមនុស្សភ្នែកក្រៅភ្លឺ ។ ទទឹមគ្នានេះ, សកលសត្វ មិនសូវបានដឹងថា ខ្លួនមានភ្នែកខាងក្នុងនិងគ្មានដឹងថា ភ្នែកខាងក្នុងរបស់ខ្លួនមានកង្វាក់ ។ ក្រៃលែងជាងនេះទៅទៀត, គឺមិនត្រឹមតែបានដឹងថា មានភ្នែកខាងក្នុង នឹងគ្មានដឹងថាភ្នែកខាងក្នុងមានកង្វាក់ប៉ុននឹងទេ, បន្ថែមលើនេះ, គឺគ្មានដឹង ថា



Websites: WatKhemaraRatanaram.org or WatKhmers.org

ភ្នែកខាងក្នុងមានប្រយោជន៍សំខាន់ជាងភ្នែកខាងក្រៅទៀតផង ។ មនុស្សយើង កាលណាបានធ្វើដំណោះស្រាយបញ្ហាជីវិត ប្រកបដោយភាពស្មុគស្មាញ ក្នុងវិស័យភ្នែកខាងក្រៅចប់ស្រេចបាច់ហើយ ។ គេក៏ត្រូវប្រឈមមុខធ្វើដំណោះស្រាយបញ្ហាជីវិត ប្រកបដោយភាពស្មុគស្មាញ ដូចគ្នាក្នុងវិស័យភ្នែកខាងក្នុងមួយទៀត, តែគេមិនស្គាល់មុខងារនៃវិស័យភ្នែកខាងក្នុងនេះជាក់លាក់ទេ ។ ប៉ុន្តែគេចេះតែធ្វើទាំងបំពានត្រោក បំពានត្រាំងទៅ ខុសខ្លះត្រូវខ្លះ រួចខ្លះមិនរួចខ្លះ បន្ទោសខ្លួនឯងខ្លះ បន្ទោសអ្នកដទៃខ្លះ ដៅស្មានដូចនេះខ្លះ ដៅស្មានដូចនោះខ្លះ ទៅតាមអារម្មណ៍និងភាពមិនច្បាស់លាស់របស់ខ្លួន ។ ដំណោះស្រាយរបៀបកំឡៅបែបនេះរបស់គេ មិនអាចជួបនូវសេចក្តីសុខដ៏ពិតប្រាកដបានឡើយ ។ នេះគឺជាលទ្ធផលនៃទំរើដំណោះស្រាយកំឡៅ, ដំណោះស្រាយប្រាសចាកហេតុផល គឺដំណោះស្រាយដែលគេធ្វើឡើងនៅលើទ្រឹស្តីគ្មានបញ្ញាចក្ខុ ។ បើនឹងស្តីអោយខ្លី លោកថា សេចក្តីសុខពិតប្រាកដកើតមិនបាន មកតែពីគ្មានប្រើភ្នែកបញ្ញាក្នុងទំរើដំណោះស្រាយ ។ ហើយដែលមិនប្រើ ក៏មកពីមិនដឹងថា ភ្នែកគឺបញ្ញា ជាធាតុមួយយ៉ាងសំខាន់ សម្រាប់មើលនិព្វាន ឬមើលភាពត្រជាក់ត្រជុំក្សេមក្សាន្តពិតប្រាកដរបស់ជីវិត ។

ចិត្តយើងខ្វាក់ព្រោះអវិជ្ជា គឺកំឡៅ ឬចំហោតយ៉ាងធំមហិមារបស់យើងហ្នឹងឯង ។ ប្រៀបបាននឹងសំបកស៊ុតមាន់ ដែលវេចខ្ចប់កូនមាន់, ដូចលលាដ៏ដូងគ្របលើសត្វដង្កូវទឹក, ដូចសំបកផ្លែឈើវេចខ្ចប់សាច់ផល, ធាតុខាងក្នុងទាំងអស់នេះ គ្មានបានដឹង គ្មានបាន



Websites: WatKhemaraRatanaram.org or WatKhmers.org

ឃើញនូវពន្លឺទាំងឡាយ មានពន្លឺដួងអាទិត្យជាដើម សូម្បីបន្តិចបន្តួចឡើយ ទោះណាជាចំហេះ ឬ ចំណាំងទាំងអស់នេះ បានបិតនៅលើខ្លួនជានិច្ចគ្រប់ពេលវេលាក៏ដោយ ។ សេចក្តីនេះយ៉ាងណាមិញ , ចិត្តសត្វលោកដែលត្រូវអវិជ្ជាវេចខ្ចប់ ក៏ពុំអាចសម្ផស្សជាមួយនឹងនិព្វានបាន យ៉ាងនោះដែរ ។

ក្នុងកាលណា សំបកនិងលលាដ៍ទាំងឡាយត្រូវបានគេបកចេញ ឬកំទេចចោល ក្នុងកាលនោះ សត្វល្អិតក្តី កូនមាន់ក្តី ពីជៈក្តី ទាំងអស់គ្នាបានឃើញពន្លឺ , បានដឹងថា ពិភពលោកមិនមែនងងឹតដូចដែលខ្លួនបានស្មានឡើយ ។ សេចក្តីនេះមានឧបមាយ៉ាងណាមិញ ។ និព្វានក៏មានឧបមេយ្យយ៉ាងនោះដែរ កាលណាចិត្តរបស់យើងបានវាយកំទេចសំបកវេចខ្ចប់ ដែលមានឈ្មោះថា អវិជ្ជា , តណ្ហា , ឧបាទាន ។ល។ គ្រប់ជាន់ថ្នាក់ ដោយកំឡាំងនៃការប្រតិបត្តិធម៌បានហើយ , កាលនោះពន្លឺនិងរសនៃនិព្វាន ក៏បានចូលមកសម្ផស្សជាមួយនឹងចិត្តភ្លាមដែរ ។ ជាមួយគ្នានេះ , យើងបានឃើញយ៉ាងច្បាស់ថា និព្វានមិនមែនចិត្ត មិនមែនចេតសិក ដែលកើតអាស្រ័យជាមួយនឹងចិត្ត , មិនមែនរូបធម៌ , មិនមែនរូបនេះ , មិនមែនលោកដទៃ , មិនមែនសកលតារា , មិនមែននៅក្នុងយើង , មិនមែនកើតអំពីយើង , គ្មានអ្វីបង្កើត , គ្មានអ្វីតុបតែង ។ល។ គឺត្រឹមតែជារបស់ចូលមកសម្ផស្សជាមួយដួងចិត្តរបស់យើង ក្នុងពេលដែលបានប្រតិបត្តិធម៌ បានសម្រេចផលកំពូល ឬផលជាទីបំផុត ដែលជាគុណធម៌វិសេស សម្រាប់ភ្ជាប់វិសុទ្ធិចិត្តរបស់យើងជាមួយនឹងនិព្វាន



Websites: WatKhemaraRatanaram.org or WatKhmers.org

ឬសម្រាប់បើកផ្លូវអោយនិព្វានចូលមកសម្ពស្សជាមួយនឹង វិញ្ញាណអនិទស្សនៈរបស់យើងប៉ុននោះ ។



Websites: WatKhemaraRatanaram.org or WatKhmers.org

## និព្វានមានភាពដូចម្តេច ?

ដូចដែលយើងបានដឹងមកហើយ ពំនោលទាំងឡាយមានតែផ្នែកដែលមិនមែន ចំណែកដែលមែន ឬដែលជាលក្ខណៈនៃនិព្វាននោះ មិនទាន់មាននៅឡើយ ។ តើនិព្វាននោះគឺជាអ្វី ? មានលក្ខណៈយ៉ាងណាទៅ ? ( មុននឹងសងចម្លើយចំពោះសំនួរនេះ , អ្នកធ្វើសំនេរសូមធ្វើសេចក្តីបញ្ជាក់ថា អ្នកសំនេរមិនទាន់បានជួប , បានឃើញ ឬបានសម្រេចនិព្វាននៅឡើយទេ , អ្នកសំនេរត្រឹមតែជាមនុស្សម្នាក់កំពុងសិក្សាស្រាវជ្រាវអំពីនិព្វាន , មានគំនិតនិព្វាន , មានឧត្តមគតិប្រកាន់យកការនិពន្ធន៍ , ការទេសន៍ , ការសន្ទនាអំពីនិព្វាន ដើម្បីជូវគំហើញរវាងពុទ្ធសាសនិកដូចគ្នា នៅក្នុងការិយាល័យស្រាវជ្រាវ គឺខួរនិងសាសនស្ថាប័នទូទៅ នៅលើបន្ទាត់នៃព្រះបរមពុទ្ធោវាទរបស់ព្រះមានព្រះភាគអង្គអរហន្តសម្មាសម្ពុទ្ធប៉ុននោះ ) ។

**និព្វាន** គឺជាសភាពមួយបែប សឹងមានសេចក្តីបរិសុទ្ធជាកំពូល មានស្ថានៈទំនេរ ប្រាសចាកទម្ងន់ , ប្រាសចាកទុក្ខ , ប្រាសចាកកំដៅ ។ល។ ពំនោលនៃសច្ចធម៌ថា ភាពត្រជាក់ត្រជុំ , ភាពក្សេមក្សាន្ត , ភាពទោល , ភាពស្ងប់យ៉ាងកំពូល ។ល។ សភាពនេះ , លោកថាមានមកមុនរបស់ទាំងពួង , ជាសភាពគ្មានគូ , គ្មានបច្ច័យ , គ្មានរចនាសម្ព័ន្ធ ហើយជាសភាពមានជានិច្ចរហូតអនន្តកាល ។ អ្នកប្រាជ្ញទាំងឡាយផ្នែកស្រាវជ្រាវ លោកពុំបានធ្វើសេចក្តីអធិប្បាយវែងឆ្ងាយទេ ។ ក្នុងឃ្លាទីបំផុតនៃទំព័រស្រាវជ្រាវរបស់



Websites: WatKhemaraRatanaram.org or WatKhmers.org

លោក , លោកគ្រាន់តែបានធ្វើសេចក្តីបញ្ជាក់យ៉ាងខ្លីថា **និព្វាន** គឺជា **អមតធម៌** ដោយលោកយល់ថា **និព្វាន** គ្មានកើត , គ្មានទៅ , គ្មានរលត់ គឺមានត្រឹមតែវត្តមានប៉ុននឹងឯង ។

ដើម្បីជាពន្លឺនៃគំនិត ក្នុងរឿងនិព្វាននេះ , អមានទាំងឡាយ សូមមេត្តាពិចារណាថា នៅក្នុងពិភពលោកយើងនេះ មានបញ្ហា ៣ ដែលគេកំពុងធ្វើវិភាគរកសេចក្តីពិត ។ បញ្ហាបីនោះ គឺបញ្ហាអទិទេព ១ , បញ្ហាធម្មជាតិ ១ , បញ្ហាវិញ្ញាណ ១ ។ បញ្ហាអទិទេពមាននៅក្នុងសាសនាព្រាហ្មណ៍ គ្រឹស្ត និងឥស្លាម ។ បញ្ហាធម្មជាតិ មាននៅក្នុងវិស័យវិទ្យាសាស្ត្រ ។ បញ្ហាវិញ្ញាណមាននៅក្នុងពុទ្ធសាសនា ។ បញ្ហាទាំង៣នេះ មួយណាក៏ដូចមួយណា ដំណោះស្រាយនិងពន្លឺនៃគំនិតដែលគេបានធ្វើមកហើយ សុទ្ធតែមានភាពស្មុគស្មាញយ៉ាងអស់សង្ឃឹម ។ ក្នុងសាសនាព្រាហ្មណ៍ , គ្រឹស្ត , និងឥស្លាម , គេបានសម្រេចនូវគំហើញរបស់គេថា អ្វីៗទាំងអស់ក្នុងសកលពិភពលោកបានត្រូវបង្កើតឡើងដោយព្រះអាទិទេព ។ គេមានគំហើញស្របគ្នាលើទំរើបង្កើត , តែមិនព្រមស្រុះស្រួលគ្នាទទួលស្គាល់ ព្រះអាទិទេពត្រឹមតែមួយអង្គរួមគ្នាទេ គឺគេបំបែកឲ្យមានព្រះអាទិទេពគ្រប់តែសាសនារៀងៗខ្លួន ហើយប្រកាន់ថា ព្រះអាទិទេពមានតែមួយព្រះអង្គ ។ គឺសាសនាព្រាហ្មណ៍ មានជំនឿថា អ្វីៗទាំងអស់ត្រូវបានបង្កើតឡើងដោយព្រះសិវៈ , គ្រឹស្តថាព្រះយ៉ៈហ្វេ , ឥស្លាមថាព្រះអាឡា ... ។ ខ្ពស់ជាងនេះទៅទៀត , ទាំងអស់គ្នា ទោះជាចង់ដឹងថា វត្តមានក្នុងខាងដើម និងអវត្តមានក្នុងខាងចុងនៃព្រះអាទិទេពរបស់



Websites: WatKhemaraRatanaram.org or WatKhmers.org

ខ្លួន ក៏ដឹងមិនបាន ។ តែទាំងអស់គ្នា មានគំហើញស្របគ្នាថា ពេលណាមួយខ្លួនស្លាប់ទៅ អាត្ម័នអស់បាបអស់គ្រឿងសៅហ្មងឬវិញ្ញាណបរិសុទ្ធរបស់ខ្លួន , នឹងបានទៅកើតរួមជាតុ រួមទី រួមភពជាមួយនឹងព្រះអាទិទេព , ហើយរស់នៅរហូតអនន្តកាល អស់មានការវិលត្រឡប់ ។

ចំណែកពុទ្ធសាសនាមិនយល់ថា មានព្រះអាទិទេព មិនអើពើដល់វត្តមាន និងអវត្តមាននៃព្រះអាទិទេពដូចសាសនាទាំងឡាយនេះទេ , តែពុទ្ធសាសនាយល់ថាមានវិញ្ញាណ , សកលសត្វ កើតរស់ដោយអាស្រ័យដំនឹករបស់វិញ្ញាណ ។ ប៉ុន្តែពុទ្ធសាសនាក៏គ្មានដឹងវត្តមាននិងអវត្តមានរបស់វិញ្ញាណក្នុងខាងដើមនិងខាងចុងឡើយ ។ នៅក្នុងបដិច្ចសមុប្បាទធម៌ ដែលសំដែងដោយព្រះសម្មាសម្ពុទ្ធ , កាលណាគេសួឲ្យប្រាស ឬ គេយកន័យពីខាងចុងទៅខាងដើម គេឃើញបានយ៉ាងច្បាស់ថា ជាតិជាបច្ច័យរបស់ភព , ភពជាបច្ច័យរបស់ឧបាទាន , ឧបាទានជាបច្ច័យរបស់តណ្ហា , តណ្ហាជាបច្ច័យរបស់វេទនា , វេទនាជាបច្ច័យរបស់ផស្សៈ , ផស្សៈជាបច្ច័យរបស់អាយតនៈ , អាយតនៈជាបច្ច័យរបស់នាមរូប , នាមរូបជាបច្ច័យរបស់វិញ្ញាណ , វិញ្ញាណជាបច្ច័យរបស់សង្ខារ , សង្ខារជាបច្ច័យរបស់អវិជ្ជា ។ បើតាមន័យនេះ , វិញ្ញាណដែលដើរតួដឹកនាំ យ៉ាងចេញមុខនូវអង្គបដិច្ចសមុប្បាទដែលប្រៀបបាន នឹងព្រះអទិទេពនោះ ក៏គ្មាននរណាអាចដឹងថាវិញ្ញាណមានមកតាំងពីកាលណា , ព្រោះបដិច្ច



Websites: WatKhemaraRatanaram.org or WatKhmers.org

សមុប្បាទសំនួចបណ្តោយ ក៏ចាប់អំពីអវិជ្ជា, សំនួចប្រាសក៏មកទល់ត្រឹមអវិជ្ជាដូចគ្នា ។

គំនិតខាងវិទ្យាសាស្ត្រថា អ្វីៗទាំងអស់នៅក្នុងសកលពិភព កើតឯង មានឯង នៅឯង តាមធម្មតានៃសភាវៈរបស់ធម្មជាតិ ។ ក្នុងន័យថា គ្មានអ្នកបង្កើត, តែក៏មិនបានដឹងថា វត្ថុធម្មជាតិឬតួធម្មជាតិ កើតមកតាំងពីកាលណា, នៅបានប៉ុន្មានរយៈកាលទៅមុខទៀត, មានការអស់ទៅក្នុងទីបំផុតនៃកាលណាមួយ ឬនៅបែបនេះរហូតជាអនន្តកាល ។

អ្នកសរសេរមានទស្សនៈថា របស់ទាំងឡាយដែលមានឈ្មោះថា "វិញ្ញាណ" ដែលមាននិយាយក្នុងបដិច្ចសមុប្បាទនៃពុទ្ធសាសនាក្តី, ដែលមានឈ្មោះថា "អាទិទេព" ក្នុងសាសនាទាំងឡាយមានសាសនាព្រាហ្មណ៍ជាដើមក្តី, ដែលមានឈ្មោះថា "ធម្មជាតិ" តាមគំនិតវិទ្យាសាស្ត្រក្តីមិនមែនជាអមតធម៌ទេ ។ តែនិព្វានដែលរកឃើញ ដោយព្រះសមណគោត្តមបរមគ្រូគឺជាអមតធម៌ ។ ព្រោះនិព្វានជាអសង្ខតធាតុ គ្មានប្រពន្ធករណីយ៍ គ្មានរចនាសម្ពន្ធជាមួយនឹងអ្វីដែលពុទ្ធសាសនាហៅថា បច្ច័យនៃកំណើត ។

ចិត្តរបស់មនុស្សយើងក្នុងទីបំផុត នឹងត្រូវបានជួបអមតធម៌នេះ យ៉ាងពិតប្រាកដ តែចិត្តក៏មិនជាអមតធម៌ឡើយ ។ និព្វានត្រឹមតែជារបស់មួយ សម្រាប់ទទួលអោយចិត្តជួប ។ កាលណាចិត្តបានជួប ចិត្តក៏បានភាពត្រជាក់ត្រជុំក្សេមក្សាន្តយ៉ាងកំពូល យ៉ាងចំលែកអស្ចារ្យ ដែលចិត្តមិនធ្លាប់មានពីមុនមក ។ មនុស្សនឿយណាយទុក្ខ



Websites: WatKhemaraRatanaram.org or WatKhmers.org

គួរខំព្យាយាមបំពេញបារមីធម៌ ដើម្បីបានសម្រេចនិព្វានមុនថ្ងៃដែលខ្លួនត្រូវស្លាប់ ។ កាលណាយើងចេះតែបណ្តែតបណ្តោយ អោយចិត្តត្រាច់រង្គត់លើផ្លូវវែងឆ្ងាយ នៅក្នុងក្របខ័ណ្ឌនៃកង្វាក់ភ្នែកក្នុង ពេលគឺបញ្ញានោះ , ជីវិតអន្ទោលរបស់យើងមុខតែនឹងចេះតែមានដដែលៗគ្មានចប់គ្មានអស់ហើយ , សង្សារវដ្តរបស់យើងនឹងចេះតែវែងសែនវែង គ្មានត្រើយ , គ្មានទីបំផុត ព្រោះតែសេចក្តីធ្វេសប្រហែសរបស់យើង ។ កាលបើកភ្នែកមើលឃើញពន្លឺនៃនិព្វាន ជាកំពូលនៃសេចក្តីរំលត់ទុក្ខ , ជាកំពូលនៃសេចក្តីប្រាថ្នាគ្រប់បែបយ៉ាង , ជាទីផុតរលត់នៃសេចក្តីសង្ស័យ ក្នុងរបស់ដែលយើងចង់ដឹងចង់ស្គាល់ , ជាកំពូលនៃសេចក្តីចេះដឹងរបស់ជីវិតក្នុងសកលលោកគ្រប់កាល គ្រប់សម័យគឺជាជោគជ័យកំពូលនៃជីវិតរបស់សត្វទាំងឡាយ ។ ប៉ុននេះ , ជាការសំដែងអោយយើងបានឃើញខ្លះហើយថា **និព្វាន** គឺជាចំនុចទិសដៅចុងក្រោយបំផុតរបស់សកលជីវិត គឺជាដំណាក់ចុងក្រោយបង្អស់នៃបារមីធម៌របស់យើងហ្នឹងឯង ។ ប្រសិនបើ មានអ្នកធ្វើសំនួរថា និព្វានគឺជាអ្វី ? មានលក្ខណៈដូចម្តេច ? នៅទីណា ? អ្នកសរសេរនឹងអោយចម្លើយ ដូចពោលមកហើយ , ហើយនឹងចេះតែអោយចម្លើយបែបនេះតទៅទៀត បើកាលណាសំនួរយ៉ាងនេះ មិនទាន់ត្រូវបានគេបញ្ចប់ ។



Websites: WatKhemaraRatanaram.org or WatKhmers.org

# សកលមនុស្សត្រូវបានទៅដល់និព្វាន

មនុស្សរាល់រូបត្រូវបានសម្រេចនិព្វាន ក្នុងពេលណាមួយមិនឆាប់ក៏យូរ, ទោះជាបច្ចុប្បន្នកាលនេះ, ឋានៈនៃខ្លួនគេជាមនុស្សល្ងង់ខ្លៅឬឆ្លៀវឆ្លាតក៏ដោយ ។ សត្វក្នុងសកលលោកត្រូវតែចប់ដំណើរអន្ទោលរបស់ជីវិត គឺបានសម្រេចនិព្វានក្នុងជាតិណាមួយ ដែលក្អែកខាងក្នុងរបស់គេបានអស់កង្វាក់ ព្រោះជីវិតសត្វាតែងតែមានទីបំផុតនៃសង្សារវដ្តដូចគ្នា ខុសគ្នាតែខ្លះយូរខ្លះឆាប់ប៉ុននោះ ។ ក្នុងន័យថាមនុស្សម្នាក់ៗត្រូវបានធម្មជាតិថ្នាក់ខ្ពស់ៗព្រយិតប្រទាញទៅរកទីចប់ទីអស់ហើយរឿយៗ ក្នុងទីបំផុតគេក៏ត្រូវបានដល់ ត្រើយរបស់ភពទាំងអស់ ។ អ្នកណាមានទម្ងន់កិលេលច្រើនត្រូវបានសំរេចនិព្វានយូរ, អ្នកណាមានទម្ងន់កិលេលតិចត្រូវបានសំរេចនិព្វានឆាប់ ។ ដូចនេះព្រោះអ្វី? ព្រោះកិលេសជាទម្ងន់របស់ចិត្តវិញ្ញាណ ដូចគ្នានឹងសម្ភារៈជាទម្ងន់របស់រូបកាយដែរ ។

តាមច្បាប់នៃការវត្តន៍ខាងវិទ្យាសាស្ត្រ សម័យបច្ចុប្បន្ន ទោះជីវសាស្ត្រទូទៅក្តី លទ្ធិដារវិនក្តី ទ្រឹស្តីនៃពុទ្ធសាសនាខាងវិស័យវិទ្យាសាស្ត្រ គឺច្បាប់នៃបច្ច័យ ២៤ និងបដិច្ចសមុប្បាទក្តី, គេសង្កេតឃើញថា សកលលោកនេះមានដំណើរវិវត្តន៍សន្សឹមៗពីថ្នាក់ទាបទៅកាន់ថ្នាក់ខ្ពស់ បើមិនរូបធម៌ ( សម្ភារៈ ) ក៏ខាងអរូបធម៌ ( ចិត្ត ) គ្មានឈប់ឈរ, គ្មានគោកគាំងដល់ម្តងណាឡើយ, ស្រេចហើយតែ



Websites: WatKhemaraRatanaram.org or WatKhmers.org

យុគសម័យនោះ ពិភពលោកអោយតម្លៃខ្ពស់ដល់ចិត្តឬអោយតម្លៃខ្ពស់ដល់រូបប៉ុននោះ ។

នេះបញ្ជាក់អោយឃើញថា សញ្ជាតញ្ញាណមនុស្សនិងវត្ថុជាតុខាងក្រៅ ពិតជាបានប្រទង់ប្រទាញមនុស្សអោយលុះចូលទៅក្នុងផ្លូវល្អបន្តិចម្តងៗ ព្រោះតណ្ហាដែលមាននៅក្នុងព្រលឹងសត្វទូទៅវាត្រូវការសេចក្តីល្អតាមធម្មតារបស់វា ។

សម័យណា សត្តានាំគ្នាផ្ចង់ចិត្តខាងរូប, វឌ្ឍនភាពរបស់សម្ភារៈ ក៏ត្រូវកើតមានក្នុងទីបំផុត ដូចវិស័យវិទ្យាសាស្ត្រ ដែលកំពុងជឿនលឿនយ៉ាងសម្បើមសព្វថ្ងៃនេះ, សម័យណាសត្វលោកមានមនសិការៈផ្ចង់ទៅខាងចិត្ត, វឌ្ឍនភាពខាងវិញ្ញាណក៏ត្រូវកើតមានក្នុងទីបំផុត ដូចវិស័យធម្មៈដែលបានជឿនលឿនក្នុងយុគនៃអរហន្តា ដែលកន្លងមកហើយ ។

តែទោះជាម្តេចម្តាក្តី សត្វលោកមិនមែនចេះតែផ្តាប់គំនិតនឹងរូបធម៌ ស្រវឹងរូបធម៌រហូតទេ, រយៈកាលចេះតែកន្លងទៅរឿយៗ, មិនយូរមិនឆាប់គេក៏ត្រឡប់មានស្មារតីភ្ញាក់រលឹក កើតមានគំនិតនឿយណាយរាងចាលចំពោះរូបធម៌ ហើយនាំគ្នាវិលមករកចិត្ត នៅក្នុងក្របខ័ណ្ឌផ្ទើដំណោះស្រាយបញ្ហាវិញ្ញាណ ។ ពេលនេះឯង



Websites: WatKhemaraRatanaram.org or WatKhmers.org

ហើយ, ដែលមានសត្វពួកមួយបានរួចផុតចាកលោក គ្រប់ពេលដែលពិភពលោកបានវិលមកដល់ចំនុចចក្រវាសីនេះ។ និយាយយ៉ាងខ្លីថា សញ្ញាតញ្ញាណរបស់សត្វលោក មួយណាក៏ដូចជាមួយណារមែងតែងវិលទៅរកសេចក្តីល្អ បើមិនខាងរូបក៏ខាងចិត្តទាំងពីរនេះណាមួយជាមិនខាន។

កាលណាសកលមនុស្សមានអំណាច " កាយសិទ្ធ៍ " នៅក្នុងខ្លួន, អំណាចនេះវាពិតជាមានអានុភាពប្រកបដោយអាថ៌កំបាំងសម្រាប់ធក់ស្រូប, សម្រាប់តភ្ជាប់, សម្រាប់ទាក់ទាញវិញ្ញាណមនុស្សទៅរកស្ថានៈ នៃដំណើរជួបជួននឹងព្រះនិព្វាន។ ក្នុងន័យថាសត្វលោកកាលណាបានដើរតួជាកូនល្ខោននៃពិភពលោក ក្នុងឆាកស្វែងកាម, ស្វែងមាន, ស្វែងគ្មានយូរទៅ គេក៏កើតគំនិតទ្រាន់ណាយចំពោះទំរើងដែលៗ ដែលខ្លួនគេបានជួបក្នុងពិភពលោក។ ជាមួយគ្នានេះ, គំនិត " និព្វិទា " ក៏កើតមានឡើងក្នុងថ្ងៃណាមួយ។ បន្ទាប់មក, គំនិតឧបាទានរបស់គេដែលធ្លាប់មានពីមុនមកក៏អស់, ចិត្តរបស់គេក៏បានដកចេញអំពីសំបកវេចខ្ចប់របស់កិលេសទាំងឡាយ មានអវិជ្ជាជាដើម។ ទីបំផុត, និព្វានក៏ចូលមកសម្ងួស្ង៌ជាមួយនឹងចិត្តរបស់គេក្នុងពេលនោះ។ មនុស្សយើងបានស្គាល់ខ្លួនឯងដោយអាស្រ័យកែវភ្នែកខ្លីៗ ក្នុងបច្ចុប្បន្នជាតិនេះ ទើបមើលចំណង់និងទំពាន់ ដែលមានសាយសម្ពន្ធន៍វែងអន្ទាយច្រើនកពមិនឃើញ។ កំលីនៃគំហើញរបស់យើងវាបានធ្វើអោយយើងយល់ច្រឡំលើគំនិតទ្រាន់ណាយ របស់យុវជនខ្លះដែលកើតមកមិនចូលចិត្តកាម



Websites: WatKhemaraRatanaram.org or WatKhmers.org

គុណ មានសេចក្តីលោភក្រោធវង្វេងតិចជាងមនុស្សទូទៅ ។ យើងមិនចូលចិត្តថា សន្តានចិត្តបែបនេះរបស់គេ គឺជាផលនៃបារមីធម៌ដែលគេបានសាងមកអំពីជាតិដែលកន្លងទៅ យើងត្រឡប់ជាមានគំហើញថាគេមានខួរក្បាលមិនល្អ ដោយសំអាងលើគំនោលការចិត្តវិទ្យាឬក្បួនតម្រាផ្សេងៗ ដែលខ្លួនចង់ផ្អែកដើម្បីបដិសេធគំនិតល្អវិសេសរបស់គេ ។ ប្រសិនបើយើងមានកែវភ្នែកវែងមើលឃើញអតីតជាតិបានច្រើន យើងមុខជាមានសេចក្តីធ្មៀវឆ្ងាតជាងនេះ ជាច្រើនរយភាគ ហើយគំហើញត្រូវរបស់យើង នឹងចូលមកជំនួសគំហើញខុសជាមិនខាន ។ តែទោះណាកែវភ្នែកវែងមានប្រយោជន៍ច្រើនយ៉ាងនេះក៏ដោយ ក៏គេមិនចង់សាងកែវភ្នែកវែងឡើយ ។

ព្រោះអ្វី ? ព្រោះមនុស្សខ្លះមិនយល់ថា សាងកើត ខ្លះនឹកខ្លាចថា កាលណាមានកែវភ្នែកវែង , គំនិតមនុស្សមុខជាធុញទ្រាន់ក្នុងទំរើសាងលោក , ពិភពលោកនឹងអស់វឌ្ឍនភាព , អស់រសជាតិឆ្ងាញ់ពិសារ ។ ការណ៍ពិត គំហើញរបស់មនុស្ស វាត្រឹមជាគំហើញប៉ុននឹងទេ , នរណាឃើញយ៉ាងម៉េចក៏ឃើញទៅ , ចុងក្រោយបង្អស់គំនិតរបស់មនុស្សនឹងត្រូវរាកវេទៅរកនិព្វានដូចៗគ្នា ព្រោះក្នុងលោកនេះ គ្មានអ្វីមានអំណាចខ្ពស់ជាងវិបាករបស់កម្ម ដែលជាវិស័យធ្លាក់ធ្មែសញ្ញាតញ្ញាណរបស់មនុស្ស អោយមានគុណភាពល្អដើម្បីអស់ទុក្ខក្នុងទីបំផុតហ្នឹងទេ ។ ខ្ពស់ជាងនេះ , គឺសច្ចធម៌វានៅជាសច្ចធម៌ គឺទុក្ខៈ សមុទយៈ និរោធៈ មគ្គៈ គ្មានដូរ , គ្មានប្រែប្រួលឡើយ ។ ប្រសិនបើមានសំនួរថា សត្វលោកបានដល់ទី អស់ទុក្ខ



Websites: WatKhemaraRatanaram.org or WatKhmers.org

ដោយអាស្រ័យចំលាក់ នៃវិបាករបស់កម្ម, ដោយអាស្រ័យការវិវត្តន៍សច្ចធម៌។ ដូចនេះ ទំរើបុណ្យកុសលមិនមែនជាធាតុចាំបាច់របស់មនុស្សទេ មនុស្សម្នាក់ៗត្រូវខំស្វែងរកសេចក្តីសុខ មកបំរើជីវិតរបស់ខ្លួន ក្នុងលោកនេះរឿយៗទៅក៏ហើយគ្នា, ទីបំផុតគង់នឹងបាននិព្វានជាមិនខាន, មិនថាអីចឹង? ចំពោះសំនួរនេះ, អ្នកសរសេរសូមអោយចម្លើយថា ពិត។ ដូចនេះ ព្រោះអ្វី? ព្រោះថាការវិវត្តន៍នៃជីវិតមនុស្សតាំងពីកាលណាកាលណីមក គេឃើញថា ចាប់ផ្តើមពីទាបទៅខ្ពស់ គឺពីគ្មានលំនៅឋានសំលៀកបំពាក់ ។ល។ រហូតដល់មានខោអាវផ្ទះសំបែង ប្រដាប់ប្រដាប្រើប្រាស់គ្រប់យ៉ាង។ ក្នុងន័យថាមនុស្សរស់នៅរបៀបសត្វរហូតដល់រស់នៅរបៀបទេវតា, រស់នៅក្នុងរូងភ្នំ ដីដំបូក រហូតដល់រស់នៅលើវិមានស្កឹមស្កៃ ។ល។ នេះមកពីអ្វី? មិនមែនមកពីវិបាកនៃកម្មបង្រៀនមនុស្សទេឬ? ជាមួយគ្នានេះទៀត, សកលសត្វរស់នៅក្នុងអន្ទង់ទុក្ខ រហូតដល់រស់នៅជាកំពូលអស់ទុក្ខអស់ព្រួយ។ នេះមកពីអ្វី? មិនមែនមកពីសច្ចធម៌បង្រៀនទេឬ? តែកុំភ្លេចថាអ្នករស់នៅដោយសេចក្តីប្រមាទ, អ្នកដើរក្នុងទីងងឹតគ្មានចង្កៀង អ្នកដើរកណ្តាលព្រៃគ្មានផែនទី គ្មានត្រូវនិចទិស, អ្នកធ្វើដំណើរគ្មានទិសដៅ, អ្នកស្វែងនិព្វានគ្មានគំនិតអដ្ឋង្គិកមគ្គៈ ។ល។ ជនទាំងឡាយនេះរស់នៅពុំបានស្រួល, ដំណើររបស់គេច្រើនមានគ្រោះថ្នាក់, ទិសដៅដែលគេចង់បានក្របានដល់, និព្វានដែលគេប្រាថ្នានៅឆ្ងាយដាច់ស្រយាល។



Websites: WatKhemaraRatanaram.org or WatKhmers.org

យើងគួរពិចារណាតទៅទៀតថា មនុស្សខ្វាក់ភ្នែកក្នុង មើលមិនឃើញពន្លឺនៃនិព្វាន ហើយប្រាថ្នាចង់បាននិព្វាន នឹងបាននិព្វានយ៉ាងម៉េច នឹងឃើញគុណតំលៃខ្ពង់ខ្ពស់នៃនិព្វានយ៉ាងណា ។ រឿងនេះ មិនពិបាកយល់ទេ , ប្រសិនបើសើរើមើលឡើងវិញ នូវគំនិតពុទ្ធសាសនាទាំងអស់ ជាពិសេសគំនិតកម្មផល និងគំនិតអរិយសច្ចៈ ។ ទន្ទឹមគ្នានេះ , យើងត្រូវគិតគូរដល់ដែរនូវគំនិតតស៊ូ ដើម្បីជោគជ័យនៅលើឧត្តមគតិ , កម្មវិធី , គំរោងការ , ទិសដៅ ។ល។ លើជោគជ័យរបស់ជីវិតដូចគ្នា , តែគ្មានឧត្តមគតិ , កម្មវិធី , គំរោងការ , ទិសដៅ ។ល។ តើគំនិតណាបានសម្រេចជោគជ័យមុនគំនិតណា ? ចំពោះសំនួរនេះ , អ្នកសរសេរសូមអោយចម្លើយថា ទំរើផ្សងព្រេងក្តី ទំរើពឹងផ្អែកលើជំនួយពួកទេពក្តី ពុំដែលមានជោគជ័យដល់ម្តងណាទេ ប្រសិនបើមានក៏មិនដែលបានមុនគេឡើយ ។



Websites: WatKhemaraRatanaram.org or WatKhmers.org

## *សំនួនៃជីវិតដើម្បីនិព្វាន*

*យើងបានដឹងគ្រប់គ្នាហើយថា សេចក្តីទុក្ខគឺជាធាតុមួយដែលសត្វមួយណាក៏ដូចជាមួយណាគ្មានចង់ជួប, គ្មានចង់បានសោះ, តែគេចមិនរួច, ចៀសមិនផុត, ព្រោះធាតុនេះ មាននៅគ្រប់ទិសទីក្នុងសង្សារភព ។ ដើម្បីទៅអោយដល់ទីបំផុតទុក្ខ, ពុទ្ធសាសនាបានបង្រៀនយើងអោយលះបង់តណ្ហា, កំទេចអវិជ្ជា, ដកគំនិតឧបាទាន ។ល។ ដោយប្រើកំលាំងបរមីធម៌ជាជំហរ, គំនិតអរិយមគ្គជាអាវុធ ។ និព្វានឆ្ងាយណាស់, តែចម្ងាយនេះអាចពង្រួញអោយខ្លីបាន ដោយស្ពានគឺបារមីធម៌ ១០ ។ អវិជ្ជាតណ្ហាជាប់ណាស់, ស្វិតណាស់, តែសង្វិតនេះគេអាចកាត់ផ្តាច់បានដោយអាវុធគឺអរិយមគ្គ ។ ដូចនេះបេក្ខជីវិតនិព្វាន, ដំបូងបង្អស់ត្រូវខំសង់ស្ពានដែលលោកអោយឈ្មោះថាបរមីធម៌១០, សង់ហើយសង់ទៀតប្រកបដោយសំនួយ៉ាងខ្លាំងក្លា លុះត្រាហើយស្រេច ។ បន្ទាប់មកត្រូវសង់គំនិតនិព្វាន ក្នុងក្របខ័ណ្ឌនៃអរិយសច្ច ឋិតនៅលើខ្សែបន្ទាត់មជ្ឈិមាបដិបទា ដែលរកឃើញដោយព្រះសម្មាសម្ពុទ្ធបរមគ្រូ ។ ក្នុងពេលកំពុងសង់គំនិតនិព្វាន អ្នកអនុវត្តអដ្ឋង្គិកមគ្គ ត្រូវកំទេចអោយសូន្យនូវគំនិតសួគ៌, គំនិតកាម ។ល។ ដែលវិញ្ញាណរបស់ខ្លួនធ្លាប់ញៀនធ្លាប់ឆ្ងាញ់ឋានសួគ៌ជាអន្ទង់កាម ជាធាតុឧបសគ្គរាំងផ្លូវនិព្វាន ។ ជនទាំងឡាយណាមានគំនិតនិយមឋានសួគ៌ ជនទាំងឡាយនោះគ្មានគំនិតនិយមនិព្វាន ។ " ឋានសួគ៌ " ជាធាតុមួយដែលសកលសត្វ*



Websites: WatKhemaraRatanaram.org or WatKhmers.org

ប្រាថ្នាចង់បាន ដោយគេប៉ាន់ស្មានថាឋានសួគ៌ពោរពេញដោយសេចក្ដីសប្បាយ ។ ឋានសួគ៌ផ្ដល់ចំណាញ់, ផ្ដល់សំនុកយ៉ាងផ្អែមអោយគេ ។ អ្នកនិយមលាភសក្ការៈ តែងបានឃោសនាបបួលអោយមនុស្សធ្វើបុណ្យដើម្បីទៅនៅឋានសួគ៌ ។ អ្នកប្រាថ្នាឋានសួគ៌ ខំប្រឹងធ្វើបុណ្យតាមគេ នៅក្នុងក្របខ័ណ្ឌនៃគំនិតកាម លុះដល់ពេលស្លាប់ទៅកើតក្នុងអន្ទង់កាម ( កាមោឃ ) គឺឋានសួគ៌ ដែលព្រះពុទ្ធបរមគ្រូបានធ្វើសេចក្ដីរិះគន់និងសេចក្ដីបដិសេធ ដោយអនុបុព្វីកថា ទី៤ និងទី៥ ។

" នរក " ជាឈ្មោះនៃក្ដីទុក្ខ, ក្ដីទារុណ ព្រោះគ្មាននុយ គឺកាមសំរាប់ផ្ដល់ក្ដីសប្បាយ, ក្ដីឆ្ងាញ់ពិសា តាមចំណង់របស់សត្វា ទើបគេមិនចង់បាន ។

តែឋានសួគ៌ ក៏មិនមែនជាឋានណាដទៃទេ គឺនរកហ្នឹងឯង ព្រោះកាលណាគេឡើងឋានសួគ៌ញយៗ គេក៏ត្រូវបានធ្លាក់នរកញយៗដែរ ។

នរក សួគ៌ ដែលត្រាស់សំដែងផ្ទាល់ ដោយព្រះសម្មាសម្ពុទ្ធមានដូចនេះ ៖

" ភិក្ខុទាំងឡាយ! វាជាលាភរបស់អ្នកទាំងឡាយហើយ, អ្នកទាំងឡាយល្អហើយ, ដែលបានមានឱកាសចូលខ្លួនមកប្រព្រឹត្តព្រហ្មចរិយធម៌ (ក្នុងសាសនាតថាគត)។ ម្នាលភិក្ខុទាំងឡាយ! អញតថាគតបានឃើញហើយ នរក និង សួគ៌ មាននៅគ្រប់អាយតនៈ៦ ដែលជាអណ្ដូងជាទីកើតនៃផស្សៈនេះឯង ។ តើនរកសួគ៌នេះមាន



Websites: WatKhemaraRatanaram.org or WatKhmers.org

ន័យដូចម្តេច? ម្នាលភិក្ខុទាំងឡាយ! គឺក្នុងពេលណា ដែល អាយតនៈខាងក្នុង៦បានជួបប្រទះរូបសម្លេង, ក្លិន, រស, ផស្សព្វ, ធម្មារម្មណ៍ជាទីប្រាថ្នា, ជាទីពេញចិត្ត, ក្នុងពេលនោះចិត្តសោយ អារម្មណ៍ជាសុខ, ជាសួគ៌"។

ពាក្យថា "នរក" ក្នុងព្រះត្រៃបិដក ឃើញមានពាក្យពីរម៉ាត់ គឺ "និរយៈ" មួយ "នរកៈ"មួយ។ "**និរយៈ**" ប្រែថាភូមិ ឬជាន់គ្មានក្តី សុខ គ្មានក្តីចំរើន។ គឺមកពីពាក្យថា "និរៈ" និង "អយៈ"។ និរៈ = គ្មាន អយៈ = ក្តីសុខចំរើន។ "**នរកៈ**" ប្រែថា "រណ្តៅ" ឬ "អន្លង់" បានដល់" រណ្តៅទុក្ខ" ឬ "អន្លង់ទុក្ខ"។

ពាក្យថា "សួគ៌" ប្រែថាភូមិ ឬជាន់ដែលមាន "អារម្មណ៍ល្អ ប្រពៃ" ឬដែល "លើសលន់ដោយអារម្មណ៍ល្អប្រសើរ" ពុទ្ធភាសិត នេះ បញ្ជាក់អោយឃើញថា នរក និង សួគ៌ មាននៅក្នុងខ្លួន ឬក្នុងចិត្ត មនុស្សយើងនេះឯង។ ជីវិតមនុស្សម្នាក់ៗ ក្នុងបច្ចុប្បន្ននេះ អាច ប្រព្រឹត្តទៅបានទាំងនរក ទាំងសួគ៌។ ពិភពលោកយើងនេះ ក៏អាច ប្រព្រឹត្តទៅបានទាំងនរកទាំងសួគ៌។ ក្នុងពេលណាអាយតនៈ ប៉ះ ពាល់ត្រូវអារម្មណ៍ផ្សេងៗ បើចិត្តសោយអារម្មណ៍ជាទុក្ខ, ជាក្តៅក្នុង ពេលនោះហៅថាធ្លាក់នរកទាំងរស់, គឺធ្លាក់ចុះក្នុងរណ្តៅនៃក្តីទុក្ខ។ ក្តីទុក្ខធំ នរកក៏ធំ, ក្តីទុក្ខតិច នរកក៏តូច។ ក្នុងពេលណាចិត្តសោយ អារម្មណ៍ជាសុខ, ជាសប្បាយរីករាយ ហៅថាឡើងសួគ៌ គឺឡើង វិមានសុខាល័យទាំងរស់។



Websites: WatKhemaraRatanaram.org or WatKhmers.org

តែទោះជាដូចម្ដេចម្នាក្ដី យើងកុំត្រូវភ្លេចអោយសោះថា ក្នុងអរិយសច្ចធម៌ លោកគ្មានបាននិយាយថា ក្ដីសុខគឺជាភាពមួយ ដែលសកលសត្វត្រូវបាន ត្រូវជួបក្នុងសកលលោក ឬ ក្នុងត្រៃភព ដល់ម្ដងណាឡើយ។ ភាសា " សុខ " គឺជាភាសារបស់មនុស្សធម្មតា ឬភាសាលោក មិនមែនជាភាសារបស់ព្រះអរហន្ត ឬនិព្វានទេ ។ ព្រោះអ្វី? ព្រោះព្រះសម្ពុទ្ធបរមគ្រូ បានប្រើពាក្យថា " សច្ចៈ " ជាស្រេចទៅហើយ , នៅលើបទថា " ទុក្ខសច្ចៈ " " សមុទយសច្ចៈ " " និរោធសច្ចៈ " " មគ្គសច្ចៈ " បានន័យថា ទុក្ខជាសភាពពិត មិនអាចក្លាយទៅជាសុខបានទេ ។ ល ។

មនុស្សយើងនឹងចុះនរក ឬឡើងសួគ៌ ស្រេចហើយតែអំពីចិត្ត ។ ចិត្តអាក្រក់ គឺចិត្តធ្លាក់ចុះក្នុងអន្លង់លោភៈ ទោសៈ មោហៈ ឬចិត្តគ្មានអប់រំដោយទំរើល្អ , ចិត្តប្រភេទនេះត្រូវធ្លាក់នរក ក្នុងលោកនេះផង ក្នុងលោកដទៃផង ។ ចិត្តល្អ គឺចិត្តដែលគេបានអប់រំដោយធម្មៈលុះត្រាមានផ្នត់គំនិតល្អ , ពំនោលថ្លៃថ្នូរ , ទំរើត្រឹមត្រូវ , ចិត្តប្រភេទនេះត្រូវបានឡើងសួគ៌ ក្នុងលោកនេះផងក្នុងលោកដទៃផង ។ អាស្រ័យហេតុដូចនេះហើយ ទើបព្រះបរមលោកនាថបានមានពំនោលថា " ព្រះសោតាបន្នៈជាបុគ្គលមាននរកអស់ហើយ , មានទ្វារនៃអបាយភូមិបិទជិតហើយ , មានចិត្តខ្ពស់លើសមនុស្សធម្មតាគ្រប់ពេលវេលា " ព្រះសោតាបន្នបុគ្គលទោះណាជាលោកនៅមានកិលេសខ្លះ ក៏លោកលែងធ្លាក់នរកហើយ ព្រោះចិត្តរបស់លោកសន្សឹមៗខ្ពស់ឡើងៗតាមលំដាប់ ។ ចំណែកមនុស្សមានចិត្តទាប ,



Websites: WatKhemaraRatanaram.org or WatKhmers.org

មានពេលខ្លះធ្លាក់នរក, មានពេលខ្លះឡើងសួគ៌, ស្រេចហើយតែអារម្មណ៍អាក្រក់ល្អអូសទាញ ។

នរកគឺជាអ្វី? សំនួរនេះ មានអ្នកអោយចម្លើយច្រើនបែបច្រើនយ៉ាងផ្សេងៗគ្នា ខ្លះថាទុក្ខ, ខ្លះថាហឹនហោច ។ល។ តែក្នុងអាទិត្តបរិយាយសូត្រ ដែលត្រាស់ដោយព្រះសម្មាសម្ពុទ្ធមានដូចនេះ

"ម្នាលភិក្ខុទាំងឡាយ ភ្នែក, ត្រចៀក, ច្រមុះ, អណ្តាត, កាយ, ចិត្តជាធាតុត្រូវភ្លើងឆេះរឿយៗ, អ្វីជាភ្លើង? រាគៈ ទោសៈ មោហៈ យើងពោលថាជាភ្លើងៈ ជាតិ, ជរា, មរណៈ, សោកៈ, បរិទេវៈ, ទុក្ខ, ទោមនស្ស, ឧបាយាសៈ ក៏យើងពោលថាភ្លើងដែរ" ។

ពុទ្ធភាសិតនេះ បានបញ្ជាក់អោយយើងឃើញថា នរកមាននៅក្នុងជីវិតរបស់យើងសព្វថ្ងៃនេះ, ភ្លើងនរកមាននៅក្នុងចិត្តរបស់យើង ។ សូមពិចារណាលើពុទ្ធភាសិតខាងក្រោមនេះ ហើយធ្វើចំនូលចិត្តដោយខ្លួនឯងៈ

"មិនមានភ្លើងណាមានកំដៅស្មើដោយភ្លើងរាគៈ ( **នត្ថិ រាគៈសមោអគ្គិ** ), ពុំមានពំនើតណា មានពិសស្មើដោយទោសៈ ( **នត្ថិ ទោសោ សមោ គហោ** ), មិនមានជាលណា មានជំនាប់ស្មើដោយមោហៈ ( **នត្ថិ មោហ សមំ ជាលំ** ), មិនមានស្ទឹងណាមានលំហូរស្មើដោយតណ្ហា ( **នត្ថិ តណ្ហា សមា នទី** )។ ជាមួយគ្នានេះ, សូមអ្នកអានមេត្តាសើរើពិនិត្យឡើងវិញ នូវពុទ្ធភាសិតដែលស្តីអំពីភ្លើងទាំង៣ ក្នុងបណ្តាល ភ្លើងទាំង៧គឺៈ **រាគគ្គិ**, **ទោសគ្គិ**, **មោហគ្គិ** ។ តើពុទ្ធ



Websites: WatKhemaraRatanaram.org or WatKhmers.org

ភាសិតនេះបានប្រាប់យើងថា រាគៈ ទោសៈ មោហៈ ជាភ្លើងមែនទេ? បើមែន! យើងត្រូវមានជំនឿប្រកបដោយសេចក្ដីក្លាហាន នៅក្នុងក្របខ័ណ្ឌនៃការបកស្រាយបំណងនៃព្រះសម្ពុទ្ធបរមគ្រូលើភ្លើង៣ ថា ព្រះអង្គប្រាកដជាចង់មានព្រះតម្រាស់ថា គ្មានភ្លើងឯណា មានកំដៅស្មើដោយភ្លើងគឺ រាគៈ, ទោសៈ, មោហៈ, ឡើយ ទោះជាភ្លើងនរកក៏ដោយ ។ គឺថាព្រះបរមសាស្ដាចារ្យ ព្រះអង្គពិតជាត្រូវការប្រើពាក្យថា " **សមោ** " នៅក្នុងចន្លោះនៃឈ្មោះកិលេស និង ឈ្មោះភ្លើងដែលមាន **នត្ថិ** នៅខាងដើមសម្រេចជារូបពាក្យថា " **នត្ថិ រាគ សមោ អគ្គិ, នត្ថិ ទោស សមោ អគ្គិ, នត្ថិ មោហ សមោ អគ្គិ** " ដូចពាក្យថា " **នត្ថិ រាគ សមោ អគ្គិ** " ដែលមានក្នុងទីដទៃដូចបានធ្វើសំនេរមកហើយក្នុងខាងដើមនោះដែរ ។ គឺភ្លើងទាំង៣នេះហើយ ដែលដុតកំទេចវិញ្ញាណមនុស្ស អោយក្លាយទៅជាវិញ្ញាណសត្វនរក ។ ដូចនេះ, យើងមិនត្រូវខ្លាចនរកក្នុងបរលោក, ហើយមិនខ្លាចនរក ក្នុងឥធលោកតាមគំហើញកំឡៅរបស់យើងឡើយ ។ ព្រោះអ្វី? ព្រោះថាបើគ្មានភ្លើងកិលេសទាំងឡាយនេះ វិញ្ញាណរបស់យើងក៏មិនត្រូវបានឆេះ ។ កាលណាវិញ្ញាណគ្មានចំហេះ វិញ្ញាណក៏មិនបានធ្លាក់នរកក្នុងជីវិតបច្ចុប្បន្ន ។ ជីវិតក្នុងលោកថ្មីក៏មិនត្រូវបានធ្លាក់នរកដូចគ្នាដែរ ។ នេះឯងគឺជាការប្រតិបត្តិធម៌ អ្នកដែលបានប្រតិបត្តិត្រូវបានឃើញផលយ៉ាងជាក់ច្បាស់ខ្លួនឯង (សន្ទិដ្ឋិកោ) ដោយមិនចាំបាច់មានអ្នកដទៃប្រាប់ឬបកឡើយ ។



Websites: WatKhemaraRatanaram.org or WatKhmers.org

" **កាម** " ជារណ្តៅនរកតាមគំហើញធម្មៈថ្នាក់ខ្ពស់ផង , តាមគំហើញប្រពៃណីផង ។ គំហើញធម្មៈ បានធ្វើសំនៅមកហើយ ។ ចំណែកគំហើញប្រពៃណី យើងអាចដឹងបានដោយអាស្រ័យរឿងសានុសាមណេរ ត្រង់ឃ្លាមួយដែលសាមណេរទ្រាន់ណាយចង់សឹក , តែម្តាយបានឃាត់ដោយប្រើពាក្យថា:

" សានុកូនម៉ែ! ម៉ែបានស្រង់អ្នកអំពីរណ្តៅនរកមកហើយ , ពេលនេះអ្នកចង់ធ្លាក់នរកទៀតឬ?" សំនួរបាលីថា: " **នរកា ឧព្ភតោ តាត នរកំ បតិតុ មិច្ឆសិ** " ឃ្លាមួយទៀត មានព្រះពុទ្ធតម្រាស់ថា:

" ម្នាលភិក្ខុទាំងឡាយ! អ្នកចូររស់នៅក្នុងធម៌ , ពិចារណាមើលធម៌ , កុំប្រមាទ , កុំភ្លេចស្មារតី , កុំបណ្តែតបណ្តោយចិត្តអោយធ្លាក់ទៅក្នុងអន្លង់កាមគុណ កុំភន្តគំនិតលេបដុំដែកក្រហម គឺបញ្ចកាមគុណ , កុំរុញខ្លួនចូលទៅក្នុងភ្នក់ភ្លើងកិលេស , មានគំនិតថា លោកនេះមានក្តីទៀងទាត់ក្តីសុខស្រួល , ក្តីបិតបេរជាស្ថាពរឡើយ " ពុទ្ធភាសិតនេះបញ្ជាក់អោយឃើញថាមនុស្សយើងត្រូវធ្លាក់នរក ក្នុងលោកនេះមុននរកក្នុងលោកដទៃ ។

បុគ្គលអ្នកសង់គំនិតដើម្បីនិព្វាន ឬបុគ្គលជាបេក្ខជននៃនិព្វាន គេរមែងមានសំនួនៅលើការងាររបស់ជីវិតទាំងលោកនេះទាំងលោកដទៃ ។ ខ្ពស់ជាងនេះ , គឺគេខំបង្កើតគំនិតស្អាត , ស្ងប់ស្ងាង , នៅក្នុងក្របខ័ណ្ឌនៃការលប់បំបាត់ នូវទំរើពុករលួយ , អយុត្តិធម៌ , បៀតបៀន ជិះជាន់ , ឈ្លានពាន ឃោរឃៅ និងគំនិតអមនុស្សធម៌ ។ល។



Websites: WatKhemaraRatanaram.org or WatKhmers.org

ជាមួយគ្នានេះ, គេខំសង់បារមីធម៌១០ នៅលើគ្រប់ខ័ណ្ឌ កំចាត់គំហើញគិតប្រយោជន៍ផ្ទាល់ខ្លួន, ស្តាបនាគំនិតទូលំទូលាយ, ឃើញទុក្ខព្រួយ, ឃើញផលប្រយោជន៍អ្នកដទៃ, ដោយប្រកាន់យកឧត្តមគតិនៃមនុស្សជាតិ និងអនុវត្តនូវគំនិតពោធិសត្វគ្រប់ពេលវេលា ។ កាលណាគំនិតដើម្បីនិព្វានមានច្រើន, គំនិតដើម្បីស្ថានសួគ៌ រមែងមានចំនួនថយចុះ ។ គំនិតនិព្វាន ជាគំនិតស្តាបនាសន្តិភាព និងវឌ្ឍនភាពគ្រប់វិស័យ ។ គំនិតឋានសួគ៌ជាគំនិតស្តាបនាសង្គ្រាម និងវិនាសកម្មគ្រប់បែបយ៉ាង ។ ដូចនេះព្រោះអ្វី? ព្រោះបុគ្គលអ្នកមានគំនិតនិព្វាន មួយណាក៏ដូចជាមួយណា តែងលះបង់ប្រយោជន៍, លះបង់សេចក្តីសុខ, លះបង់វឌ្ឍនភាពផ្ទាល់ខ្លួន ។ល។ ដើម្បីបំពេញកង្វះអ្នកដទៃជានិច្ច ។ ទំរើនេះ មិនត្រឹមតែជាជាតុបំបាត់ជម្លោះ សំអប់ និង សង្គ្រាមប៉ុននឹងទេ, បន្ថែមលើនេះ គឺបង្កើតនិងបង្កើននូវមិត្តភាព វឌ្ឍនភាព សន្តិភាព សម្រាប់សកលជីវិត សម្រាប់សកលពិភពតាំងពីពេលនេះរហូត លុះត្រាសម្រេចនិព្វានជាចុងក្រោយបង្អស់នៃធម្មជាតិ ។ ក្នុងន័យថា គំនិតនិព្វានជាគំនិតបំរើសន្តិធម៌ បំរើឧត្តមគតិមនុស្សជាតិ ។ល។

ចំណែកគំនិតឋានសួគ៌ ជាគំនិតបំរើតណ្ហា បំរើសេចក្តីសុខផ្ទាល់ខ្លួន ។ល។

បារមីធម៌១០ ដែលពុទ្ធសាសនិកយើងធ្លាប់ស្គាល់មកហើយ, ធម៌នេះមានមុខងារផ្តល់ប្រយោជន៍ ផ្តល់សេចក្តីសុខ ផ្តល់វឌ្ឍនភាពគ្រប់វិស័យ, ផ្តល់មគ្គផលនិព្វានអោយសកលមនុស្ស ជាធម៌ដែល



Websites: WatKhemaraRatanaram.org or WatKhmers.org

បង្កើតឡើងដោយបេក្ខជននិព្វានឬពោធិសត្វទាំងឡាយ , ហើយត្រូវបានសំដែងនិងប្រកាសអោយប្រើ ដោយព្រះសម្មាសម្ពុទ្ធបរមគ្រូ ។

បារមីធម៌១០ មានដូចនេះ ៖

១. ទាន:
២. សីល:
៣. នេក្ខម្ម:
៤. បញ្ញា
៥. វិរិយ:
៦. ខន្តិ
៧. សច្ច:
៨. អធិដ្ឋាន
៩. មេត្តា
១០. ឧបេក្ខា ។

**ទាន:** ជាមនុស្សត្រូវសិក្សារឿយៗ , អប់រំខ្លួនឯងញយៗ អោយយល់ស្គាល់បញ្ហាមនុស្សដើម្បីសាងទាន ។ គឺរកអោយឃើញថា មនុស្សមានភាពយ៉ាងណា គួរផ្តល់អំណោយ , យ៉ាងណាមិនគួរផ្តល់អំណោយ ។ អោយដើម្បីអ្វី មិនអោយបានទេ , អោយនិងមិនអោយណាខុសណាត្រូវ , ណាមានប្រយោជន៍ , ណាគ្មានប្រយោជន៍ ។ នេះគឺជាន័យឬ បញ្ហារបស់ទាន ។ និយាយខ្វីគឺធ្វើ



Websites: WatKhemaraRatanaram.org or WatKhmers.org

អំណោយដើម្បីប្រយោជន៍អ្នកដទៃ, ដើម្បីជាជំនួយដល់អ្នកមានកង្វះ, ដើម្បីបំរើឧត្តមគតិនៃមនុស្សជាតិប៉ុននោះ ។ល។ ដូចនេះ អំណោយរបស់បេក្ខជននិព្វាន មិនមែនជាអំណោយទាមទារយកសួគ៌វិមាន, យកមុខមាត់, យកកេរ្តិ៍ឈ្មោះ ដូចពាក្យឃោសនាដែលជនខ្លះបានធ្វើ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ហើយសំដែងគំនិតបោកក្នុងគោលគំនិតចង់រស់នៅលើកំឡាំងអ្នកដទៃ ដែលធ្លាប់មានមកជាមួយសង្គមមនុស្សក្នុងសម័យបូរាណ ឬសម័យទំនើបនេះ ។ល។

**សីល:** ជាមនុស្សត្រូវសិក្សារឿយៗ អំពីបញ្ហាមនុស្សដើម្បីបញ្ជាខ្លួនឯងអោយរស់នៅក្នុងសង្គមប្រកបដោយវិន័យ, ច្បាប់, ធម្មៈ ។ល។ ក្នុងគោលគំនិតផ្តល់ប្រយោជន៍អោយអ្នកដទៃ ខាងផ្លូវប្រតិបត្តិកាយវាចាអោយបានប្រសើរ នៅលើក្របខ័ណ្ឌនៃយុត្តិធម៌និងឧត្តមគតិនៃមនុស្សជាតិប៉ុននោះ ។ល។ ដូចនេះសិលធម៌របស់បេក្ខជននិព្វាន មិនមែនជាធាតុទាមទារយកប្រយោជន៍ផ្ទាល់ខ្លួនជាសួគ៌វិមាន ឬជាមុខមាត់កេរ្តិ៍ឈ្មោះអ្វីៗឡើយ ។

**នេក្ខម្មៈ** ជាមនុស្សត្រូវសិក្សាអោយបានចេះដឹង អំពីបញ្ហាចេញចាកកាមារម្មណ៍, ចេញចាកគំនិតញៀន, គំនិតស្រវឹង គំនិតពុករលួយ ទោះជាក្នុងឋានសួគ៌ក្តី ក្នុងឋានមនុស្សក្តី ។ ក្នុងន័យថា ខំធ្វើយ៉ាងណាកុំអោយខ្លួនធ្លាក់ចុះជាទាសភាពនៃកាមារម្មណ៍ ឬតណ្ហា ។ គឺធ្វើចិត្តនៃអាត្មាអោយជាម្ចាស់នៃអារម្មណ៍, ម្ចាស់តណ្ហា, ម្ចាស់ឋានសួគ៌ជានិច្ច ។ល។ ដូចនេះ, ទើបនេក្ខម្មៈមានទិសដៅ, មានឧត្តមគតិមនុស្ស, មានមនសិការសន្តិភាពដូចក្តីសង្ឃឹមរបស់



Websites: WatKhemaraRatanaram.org or WatKhmers.org

សកលសត្វក្នុងត្រៃលោក ។ នេះឯងគឺជាការផ្ដល់ប្រយោជន៍អោយអ្នកដទៃតាមផ្លូវនៃកម្មៈ ដែលត្រូវសត្រាយទុកមកដោយព្រះបរមពោធិសត្វ ។

**បញ្ញា** ជាមនុស្សត្រូវតែខំរៀន , ខំស្ដាប់ , ខំគិត , ខំសួរ , ខំសរសេរ ។ល។ ដើម្បីអោយវិញ្ញាណរបស់ខ្លួនមានពន្លឺ មានចន្ទុះនៅជុំវិញធម្មជាតិ , ជុំវិញសង្គតធម៌យ៉ាងត្រចះត្រចង់ សម្រាប់សងសំនួរ , អោយចម្លើយលើបញ្ហាគ្រប់វិស័យបាន , យ៉ាងដូចលោកវិទូនិងទស្សនវិទូទាំងឡាយ ក្នុងសកលលោក ដែលមានពន្លឺគំនិតហើយប្រើពន្លឺទាំងឡាយនេះ ដើម្បីប្រយោជន៍ដល់អ្នកដទៃ នៅក្នុងក្របខ័ណ្ឌនៃទំរើរដោះទុក្ខ , ចំរើនសុខដល់ពួកមនុស្ស ។ល។

**វិរិយៈ** ជាមនុស្សត្រូវខំបណ្ដុះគំនិតកំហំ , គំនិតសំនួ , គំនិតអំណត់ , គំនិតសំណង់ ។ល។ ដើម្បីផ្ដល់ប្រយោជន៍អោយមនុស្សដែលនៅរស់ជុំវិញខ្លួន នៅក្នុងប្រទេស , នៅក្នុងសកលលោក នៅក្នុងក្របខ័ណ្ឌនៃព្រហ្មវិហារធម៌ និង សម្បជញ្ញៈនៃមនុស្សជាតិ ។ និយាយដោយខ្លីគឺៈ ខំស្ដាបនាខ្លួនដើម្បីប្រយោជន៍ដល់ជាតិ , ដល់សកលជាតិ ប្រកបដោយគំនិតមនុស្សធម៌ និង អរិយធម៌ ដែលបង្កើតឡើងដោយអំបូរពុទ្ធង្កូរ ( ពុទ្ធង្កូល ) ។ល។

**ខន្តិ** ជាមនុស្សត្រូវខំរៀនអត់ , រៀនធន់, រៀនស៊ូ , រៀនទ្រាំ , រៀនប្រយុទ្ធនឹងគំនិតពុករលួយ , គំនិតអយុត្តិធម៌ , គំនិតជិះជាន់ , គំនិតឃើញប្រយោជន៍ផ្ទាល់ខ្លួន ។ល។ ក្នុងន័យថា ខំអត់ទ្រាំយ៉ាងប្តូរផ្តាច់ ដើម្បីស្ថាបនាខ្លួននៅលើបន្ទាត់នៃឧត្តមគតិផ្ដល់ប្រយោជន៍



Websites: WatKhemaraRatanaram.org or WatKhmers.org

អោយអ្នកដទៃ ប្រកបដោយគំនិតសន្តិភាព និងគំហើញព្រហ្មវិហារ ។ល។

**សច្ចៈ** ជាមនុស្សត្រូវខំរៀនអោយចេះដឹងយល់ស្គាល់នូវសច្ចធម៌ ហើយខំបណ្តុះនូវសច្ចធម៌ អោយកើតមានឡើងក្នុងវិញ្ញាណរបស់ខ្លួន ទាំងវចីសច្ច, សម្មតិសច្ច, សភាវសច្ច, បរមត្ថសច្ច, អរិយសច្ច, និងនិព្វានសច្ច ។ គឺខំប្រឹងធ្វើយ៉ាងណាលុះត្រាខ្លួនមានសច្ចធម៌ ។ ជាពិសេស, សច្ចធម៌ចំពោះខ្លួន, ចំពោះមនុស្សដទៃ, ចំពោះពេលវេលា ។ល។ និយាយដោយខ្លីគឺ អនុវត្តពាំនោល, អនុវត្តទំរើ, អនុវត្តគំនិតអោយពិតប្រាកដ តាមសំដី, គំរោងនិងគំរេះ ផ្អែកលើសច្ចភាពទូទៅ ។ ប្រែថា ទៀងត្រង់នឹងកំណើតមនុស្ស មិនបណ្តោយឲ្យកំណើតនេះ ទៅជាកំណើតសត្វតិរច្ឆាន ... ទៀងត្រង់ចំពោះពេលវេលា មិនធ្វើអ្វីៗទាំងអស់ឲ្យខុសណាត់, ខុសសន្យា, ខុសកាលកំណត់ ។ល។

**អធិដ្ឋាន** ជាមនុស្សត្រូវខំរៀនហ្វឹកហាត់ អប់រំខ្លួនអោយរស់នៅក្នុងភាពជាក់លាក់, ភាពមាំមួន, ភាពរឹងពឹង, ភាពនឹងនរ, ភាពស៊ុបសួន គឺកាលណាបានដាក់ចិត្តឬសំរេចចិត្តលើទំរើណា, ជាតុណា, គោលការណាឬកម្មវិធីណាហើយ, ខំធ្វើហើយធ្វើទៀតលុះត្រាបានសម្រេចដូចក្តីប៉ងប្រាថ្នា មិនដក, មិនគ្រវែងចោល ប្រសិនបើគ្មានបញ្ហាអំពីវិចារណញ្ញាណ ឬតម្រូវអំពីហេតុផល ដើម្បីប្រយោជន៍និងអ្នកដទៃ ។ល។



Websites: WatKhemaraRatanaram.org or WatKhmers.org

**មេត្តា** ជាមនុស្សត្រូវខំបង្កើតក្តីស្រឡាញ់រាប់អាន ចំពោះសកលសត្វ ស្មើនិងស្រឡាញ់រាប់អានខ្លួនឯងឬខ្ពស់ជាងដោយគ្មានរើសមុខ, រើសជាតិសាសន៍ អម្បូរត្រកូលវណ្ណៈពណ៌សម្បុរ ។ល។ នៅក្នុងក្របខ័ណ្ឌនៃកក្តីភាពយ៉ាងបរិសុទ្ធ យ៉ាងស្មោះស្ម័គ្រ ប្រកបដោយមនុស្សធម៌គ្រប់ពេលវេលា ។ ក្នុងន័យថា ស្រឡាញ់ស្មោះ ជួយស្មោះ រាប់អានស្មោះនៅលើឧត្តមគតិកើតដើម្បីជួយ រស់ដើម្បីមិត្ត ... ។

**ឧបេក្ខា** ជាមនុស្សត្រូវរៀនប្រើគំហើញខ្ពស់ ចិន្តាជ្រៅ គំនិតវែងជុំវិញសកលជាតុនិងសកលជីវិត នៅក្នុងក្របខ័ណ្ឌនៃសច្ចធម៌ គឺធ្វើទានដើម្បីទាន កាន់សីលដើម្បីសីល សាងនេក្ខម្មៈ ដើម្បីនេក្ខម្មៈ ។ល។ ក្នុងន័យថា ធ្វើទានដើម្បីជួយអ្នកក្រ ឃើញទុក្ខអ្នកក្រ ឃើញកង្វះអ្នកក្រ ... កាន់សីលដើម្បីយុត្តិធម៌នៃសង្គម, ឃើញទុក្ខមនុស្សទន់ខ្សោយ ឃើញចិត្តថ្លើមអ្នកតូចតាច ឃើញកំឡាចសកលសត្វ ... សាងនេក្ខម្មៈ ដើម្បីសុខស្ងប់នៃសង្គម, ឃើញទោសកាមគុណ ឃើញពិសកំណាចនៃតណ្ហា ... ។ ប្រែថា មិនធ្វើទានដើម្បីមាន, ដើម្បីយកឈ្មោះ, ដើម្បីអំនួតនៅក្នុងក្របខ័ណ្ឌនៃគំនិតជិះជាន់អ្នកក្រ, គំនិតលើកខ្លួនឯងបន្ទាបអ្នកដទៃ ។ល។ មិនកាន់សីលដើម្បីអួតល្អ, ដើម្បីលាក់ទំរើពុករលួយ, ទំរើអយុត្តិធម៌ ។ល។ មិនសាងនេក្ខម្មៈ ដើម្បីបោកសង្គម ដើម្បីក្រពះ ដើម្បីបំរើកាម ដើម្បីលើកទំរើអយុត្តិធម៌ ។ល។ ខ្ពស់ជាងនេះ, គឺមិនធ្វើចិត្តអោយសប្បាយរីករាយចំពោះទំរើដែលខ្លួនធ្វើបានសម្រេច និងមិនថ្នាំងថ្នាក់តូចចិត្តចំពោះទំរើ ដែលខ្លួនធ្វើមិនបានសម្រេច, មិនធ្វើបុណ្យនៅក្នុងក្របខ័ណ្ឌនៃសេចក្តី



Websites: WatKhemaraRatanaram.org or WatKhmers.org

ត្រេកអរ[2] , តែធ្វើបុណ្យនៅលើឧត្តមគតិ នៃគំហើញខ្ពស់[3] និងគំនិតត្រៃលក្ខណ៍ ។ល។

យើងបានស្គាល់នរក ដែលកើតឡើងក្នុងចិត្តឬនរកជាធម្មាធិដ្ឋាន ដែលសំដែងដោយព្រះសម្មាសម្ពុទ្ធ ត្រង់ចំណុចថា " **រាគគ្គិ , ទោសគ្គិ , មោហគ្គិ** " ហើយ ។ ទន្ទឹមគ្នានេះ , យើងត្រូវស្គាល់នរកជាបុគ្គលាធិដ្ឋានដែលកើតលើរូបកាយនៃមនុស្សក្នុងជីវិតសព្វថ្ងៃដែលអោយឈ្មោះដោយព្រះសម្មាសម្ពុទ្ធថា " **មនុស្សនិរយកោ** " ជាមនុស្សសត្វនរក , បានដល់មនុស្សដែលរស់នៅក្រោមទំរើកៀបសង្កត់ , ទំរើទារុណទាំងឡាយ មានទាត់ធាក់ចាក់កាប់ជាដើមឬគ្រឿងឧបករណ៍ស្ដាបនាទុក្ខទាំងឡាយមានជើងក្អើង ទឹកក្ដៅ រំពាត់ ដំបង ដាវ លំពែង គុក ច្រវាក់ ជាដើម ។ កាលណាយើងស្គាល់នរកជាធម្មាធិដ្ឋាន និងនរកជាបុគ្គលាធិដ្ឋានក្នុងលោកនេះហើយ , យើងមិនអាចនឹងមិនស្គាល់ ឬមិនយល់នូវនរកដែលយើងត្រូវបានជួបប្រទះក្នុងលោកដទៃឡើយ ។ ដូចនេះ ព្រោះអ្វី? ព្រោះនរកជាធម្មាធិដ្ឋានឬនរកក្នុងចិត្ត កើតមានឡើងដោយអាស្រ័យភ្លើងគឺ រាគៈ , ទោសៈ , មោហៈ , នរកជាបុគ្គលាធិដ្ឋាន ឬនរកលើរូបកាយ កើតមានឡើងដោយអាស្រ័យ **ចិត្តនរក** ឬ **វិញ្ញាណនរក** ហ្នឹងឯង។

ព្រះសម្មាសម្ពុទ្ធ បានមានគំហើញក្នុងរឿងនេះថា សកលសត្វរស់នៅក្នុងអន្ទង់កាម , អន្ទង់ភព , អន្ទង់ទិដ្ឋិ , អន្ទង់អវិជ្ជា

---

[2] សេចក្ដីត្រេកអរ " សោមនស្ស "។

[3] គំហើញខ្ពស់ " ឧបេក្ខា "។



Websites: WatKhemaraRatanaram.org or WatKhmers.org

( **កាមោឃៈ , ភវោឃៈ , ទិដ្ឋោឃៈ , វិជ្ជោឃៈ** ) ។ល។ ជាមួយគ្នានេះ , ព្រះអង្គមានគំហើញថា បារមីធម៌១០ ជាស្ពានឆ្លងចាកអន្លង់ទាំងឡាយទៅកាន់ត្រើយអស់ទុក្ខគឺនិព្វាន ។ ខ្ពស់ជាងនេះ ព្រះសម្មាសម្ពុទ្ធ បានមានគំហើញថា **ទុក្ខ** ជាផលរបស់ **សមុទ័យ** ឬ តណ្ហា , **និរោធ** ជាផលរបស់ មគ្គ ឬមជ្ឈិមាបដិទា ។ ព្រះគំហើញនេះ បញ្ជាក់អោយដឹងថាសកលពិភពបិតនៅក្នុងភាពលំបាកលំបិន , ភាពក្តៅក្រហាយមិនមែនបិតនៅក្នុងភាពសុខស្រួល ភាពត្រជាក់ត្រជុំឡើយ ។ " លំបាកខ្លាំង " ព្រះសម្មាសម្ពុទ្ធប្រើភាសាថា " **ទុក្ខ** " " លំបាកស្រាល " ប្រើភាសាថា " **សុខ** " ដែលយើងធ្លាប់ស្គាល់តាមភាសាមនុស្សថា " **ទុក្ខធ្ងន់** " " **ទុក្ខស្រាល** " ឬ " **ទុក្ខធំ** " " **ទុក្ខតូច** " ព្រោះ " **ទុក្ខ** " ប្រែថា " **អត់បានយ៉ាងលំបាក** " ឬ " **អត់បានយ៉ាងតឹង** " " **សុខ** " ប្រែថា " **អត់បានយ៉ាងធូរ** " ឬ " **អត់បានយ៉ាងងាយ** " ។ ប្រសិនបើមនុស្សយើងមានឧត្តមគតិយ៉ាងឧត្តមគតិនៃពោធិសត្វ ឬ បេក្ខជននៃនិព្វាននោះ , សកលជីវិតនិងមានភាពសន្តិភាពសម្បូណ៌សប្បាយ ។ ទន្ទឹមគ្នានេះ ពិភពលោកដែលកំពុងត្រូវឆេះដោយភ្លើងសង្គ្រាម នឹងត្រូវបានក្លាយជាពិភពនៃអរិយមេត្តេយ្យ ( ព្រះសិអារ្យមេត្រី ) ជាទីគួរអោយចង់រស់ចង់នៅចង់ឃើញ នៅក្នុងក្របខ័ណ្ឌនៃសេចក្តីអាឡោះអាល័យ បើមិនច្រើនក៏តិចដែរ។



Websites: WatKhemaraRatanaram.org or WatKhmers.org

# និព្វានទៅឯណា?

និព្វានគឺជាអ្វី? សំនួរនេះអ្នកធ្វើសំនេរ[4] បានអោយចម្លើយមកហើយក្នុងខាងដើមទោះសព្វគ្រប់ក្តី មិនសព្វគ្រប់ក្តី ។ អ្នកសរសេរមានសេចក្តីសង្ឃឹមថា ចម្លើយនេះគង់មានពន្លឺដល់គំនិតអ្នកអានខ្លះៗជាមិនខាន ។ នៅក្នុងឃ្លានេះទៀត អ្នកអាននឹងបានដឹងរឿងនិព្វាន ក្នុងចំណុចនៃសំនួរថា នៅឯណា ត្រូវបានសម្រេចក្នុងជាតិនេះ ឬស្លាប់ហើយទើបបានសម្រេចក្នុងជាតិមុខ ។ ដើម្បីជាពន្លឺដល់គំនិតអ្នកអាន ក្នុងរឿងនេះ អ្នកសរសេរសូមធ្វើសេចក្តីបញ្ជាក់ថា មនុស្សយើងចូលចិត្តសង់និព្វាន ឬបង្កើតនិព្វានខ្លួនឯង មិនចូលចិត្តស្វែងរកនិព្វានស្រាប់ដែលរកឃើញដោយព្រះសម្មាសម្ពុទ្ធឡើយ ។ ចំណូលចិត្តដូចនេះហើយដែលបានផ្តល់អោយគេនៅគំនិតគួសដៅ ឬគំនិតប៉ាន់ស្មានថា និព្វានជាធាតុមានផ្ទះមាស, ផ្ទះប្រាក់, មានកំពែងដាំពេជ្រ, មានថ្នល់ក្រាលកែវ, មានកោះជាពំនឹងយ៉ាងមាំ, មានលេនដ្ឋានជាជំរកយ៉ាងពូកែ, មានទីពំនាក់យ៉ាងរឹងពឹងមានអ្វីទាំងអស់ប្រកបដោយតំលៃយ៉ាងខ្ពស់បំផុត ដោយគុណភាពយ៉ាងកំពូល ដែលត្រៃលោកមិនធ្លាប់បានស្គាល់មិនធ្លាប់បានឃើញ ។ល។ តែការណ៍ពិត និព្វានជាធាតុមានឯង ។ កើតឯងៗ ប្រាកដឯងៗ មិនមែនជាសំណង់របស់មនុស្សណាម្នាក់ ឬព្រះអាទិទេពអង្គណាមួយឡើយ ។

---

[4] អ្នកធ្វើសំនេរ " អ្នកនិពន្ធ "



Websites: WatKhemaraRatanaram.org or WatKhmers.org

និព្វានភាព មានជានិច្ច ជានិរន្តរ៍ ជាអនន្តកាល ហើយជាភាពគ្មានភព គ្មានឋាន គ្មានផ្ទះសំបែង គ្មានប្រាសាទវិមាន ។ល។ និង ។ល។

ខាងក្រោយពុទ្ធកាល, ការសិក្សាមានភាពរីកចំរើន, សម្បូណ៌គម្ពីរក្បួនខ្នាត, សម្បូណ៌តម្រាវណ្ណកម្ម ។ អ្នកសិក្សា, អ្នកស្រាវជ្រាវ, អ្នកធ្វើវិភាគពុទ្ធវចនៈ សម្បូណ៌ចាក់គរដូចដើមផ្សិតលើគ្រឡាមហាប្រឹថពី ។ និព្វាន, ទើបត្រូវគេបញ្ញត, គេដាក់ឈ្មោះ, គេបកស្រាយ, គេអោយយោបល់ផ្សេងៗ តាមគំនិត, តាមវិចារណញ្ញាណរៀងៗខ្លួន ។ និព្វាន, ទើបមានឈ្មោះវេវចនៈ, ឈ្មោះប្រដូច, ឈ្មោះប្រៀបធៀប, ឈ្មោះប្រហាក់ប្រហែល កាន់តែច្រើនឡើងៗ ។ និយាយខ្លី គឺមានន័យយ៉ាងពិស្តារទូលំទូលាយគ្មានទីចប់ គ្មានទីអស់ហើយ ។ សម្ដេងថា " និព្វាន " ក៏ចេះតែមានអត្ថ មានន័យវេម្ដងបន្តិចៗទៅតាមសម្ដេង ឬសព្ទថ្មីដែលគេបញ្ញតឡើង ឬគំនិតថ្មីដែលគេដាក់បញ្ចូលមក សឹងមានចែងក្នុងគម្ពីរទាំងឡាយមានដូចនេះ ៖

១. និព្វានជាដែនស្ងប់, ជាទីគ្មានទុក្ខ, រំលត់សង្ខារ, រំលាយអវិជ្ជា ឬវដ្ដសង្សារ ។ ក្នុងន័យថា ដែននោះទីនោះ ជាដែន ជាទីស្ងប់ អស់សង្ខារ អស់វដ្ដសង្សារ ។ល។

២. និព្វានជាគ្រឿងឧបករណ៍ ជាធម្មជាតិធ្វើអោយអស់សកលកិលេស អស់គ្រឿងអសវៈ ។ សកលសត្វ អាស្រ័យពឹងផ្អែកលើនិព្វាន ទើបសម្លាប់កិលេស សម្លាប់អសវៈបាន ។ល។



Websites: WatKhemaraRatanaram.org or WatKhmers.org

៣. និព្វាន ជាកិរិយាអករៈ គឺជាចំនុចអស់កិលេស រលត់សង្ខារ សូន្យឧបាទាន រលាយនូវកិលេសយ៉ាងកំពូលគឺលោភៈ ទោសៈ មោហៈ ។ល។

៤. និព្វាន ជាផលនៃការអស់កិលេស ជាបរមសុខ ជាភាពត្រជាក់ត្រជុំ គ្មានគ្រឿងចាក់ដោត គ្មានគ្រឿងដុតបំពក់ វាជាតុទំនេយ៉ាងកំពូល ។ល។ និង ។ល។

ពំនោលក្នុងទីដទៃទៀតថា និព្វានជាធាតុវិសេសដែលសកលសត្វ ត្រូវដឹងត្រូវស្គាល់ ព្រោះនិព្វានជាផ្លូវចុងក្រោយបង្អស់របស់ធម្មជាតិ ។ អ្នកនិពន្ធបានឃើញព្រះត្រៃបិដកមួយកន្លែង អោយឈ្មោះនិព្វានថា " វិញ្ញាណ " តែមិនមែនចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជីវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ ក្នុងប្រភេទខន្ធ ៥ ឬវិញ្ញាណណាៗទៀត ដែលមាននិយាយក្នុងទីដទៃឡើយ ។ ពាក្យថា " វិញ្ញាណ " ក្នុងទីនេះ លោកអោយប្រែ អោយប្រកាន់យកសេចក្តីថា និព្វានគឺជាធាតុមួយដែលសកលសត្វត្រូវស្គាល់ ត្រូវដឹងត្រូវឃើញច្បាស់ ដោយអាស្រ័យវិញ្ញាណ ។ បើគ្មានវិញ្ញាណដើរតួ ឬគ្មានវិញ្ញាណជាប្រធានក្នុងរឿងនេះ , ពំនោលថា " និព្វាន " ក៏គ្មានដែរ។ បានន័យថា របស់ដែលសកលសត្វត្រូវដឹងក្នុងទីបំផុត ឬដំណឹងដែលសកលសត្វត្រូវដឹង ត្រូវឃើញជាចុងក្រោយបង្អស់អំពីធម្មជាតិនោះ គឺនិព្វានហ្នឹងឯង ។ ដូចនេះ ទើបលោកយកវិញ្ញាណធ្វើជាឈ្មោះនៃនិព្វាន ព្រោះនិព្វាន គេស្គាល់បានដោយវិញ្ញាណវិសេស



Websites: WatKhemaraRatanaram.org or WatKhmers.org

តាមពុទ្ធតម្រាស់ថា " **វិញ្ញាណំ អនិទស្សនំ** " តែវិញ្ញាណមិនមែនជាតួ ឬ ជាភាពនៃនិព្វានឡើយ ។

ក្នុងរឿងនិព្វានដដែល មានពំនោលខ្លះទៀតថា និព្វានជាធម្មៈ ជាធម្មៈប្រសើរកន្ទង់ ជាធម្មៈកំពូល ជាកោះ ជាពំនឹង ជាកន្លែងតទល់សត្រូវ ជាកំពែងការពារទុក្ខ ។ល។ និព្វានបែបនេះនិយាយមួយថ្ងៃវាល់ល្ងាចក៏មិនចប់ ហើយមិនដឹងថានិព្វានគឺជាអ្វីផង ។ ក្រៅពីនេះមានពំនោលថា និព្វានជាអមតធម៌ ជាអសង្ខតធម៌ ជាវិសង្ខារ ជាអព្យាកតៈ (គឺអោយឈ្មោះថាជាអ្វីក៏មិនបាន) ។ ជាមួយគ្នានេះទៀត និព្វានត្រូវបានអោយឈ្មោះថា ជានគរ, ជាអមតមហានគរ, ជាសវិមោក្ខ, ជាមហាអមតៈ ។ល។ និព្វាន ដែលត្រូវបានគេសន្មតទៅ ជាស្រុក ប្រទេស នគរ ។ល។ នោះ គឺធ្វើឡើងក្នុងបំណង អោយមនុស្សធ្វើបុណ្យយ៉ាងច្រើន, យ៉ាងប្រញាប់ប្រញាល់ប្រយោជន៍ដើម្បីខ្លួនបានប្រយោជន៍ផ្ទាល់ខ្លួនបានសម្រេចនិព្វាន ឬចូលទៅនៅក្នុងនគរ គឺនិព្វាននោះ ។ និព្វានមានឈ្មោះច្រើនលើសនឹងនិយាយលុះត្រាចុងក្រោយបង្អស់ មានគំហើញខ្លះៗទៀតថា និព្វានជាកំពូលទំនេ ជាបរមសុញ្ញតា គឺជាធាតុទំនេយ៉ាងកំពូលក្នុងទីបំផុតនៃធម្មជាតិ ។ នេះគឺជានិព្វានតាមន័យនៃបរិយត្តិធម៌ខាងផ្នែកប្រកួតចំណេះ សឹងនិយាយគ្នាអស់ថ្ងៃ ខែ ឆ្នាំ ប៉ុន្មានក៏មិនចប់ ។

ពំនោលទាំងឡាយអំពីរឿងនិព្វាន ដូចបានធ្វើសំនេរមកនេះ យើងមានគំហើញថា បើនិព្វានកើតឡើងព្រោះឃើញ **អនិច្ចំ** ហៅថា " **អនិមិត្តនិព្វាន** ", បើនិព្វានឡើងព្រោះឃើញ **ទុក្ខំ** ហៅថា



Websites: WatKhemaraRatanaram.org or WatKhmers.org

"**អបណិហិតនិព្វាន**", បើកើតឡើងដោយឃើញ **អនត្តា** ហៅថា "**សុញ្ញតនិព្វាន**", ការទុកដាក់ ឬ អោយឈ្មោះនិព្វានបែបនេះ គ្មានទីបំផុត គ្មានពេលចប់ឡើយ ។

ពំនោលក្នុងក្បួនតម្រាក្រោយៗ, និព្វានមានឈ្មោះច្រើនបែបច្រើនយ៉ាងទៀត ដែលអ្នកមានគំនិតមិនងាយនឹងមានជំនឿ, មិនងាយនឹងយល់ស្របតាម, ដូចពំនោលថាកិលេសនិព្វាន, ខន្ធនិព្វាន, ធាតុនិព្វាន ។ គឺព្រះពុទ្ធត្រាស់ដឹង ព្រោះអស់កិលេស ហៅថា "**កិលេសនិព្វាន**" រាងកាយរបស់ព្រះអង្គរលត់រលាយ ហៅថា "**ខន្ធនិព្វាន**" ព្រះធាតុក្នុងទីផ្សេងៗរួមចូលគ្នា កើតបានជាព្រះពុទ្ធអង្គម្តងទៀត សំដែងធម៌ប្រោសសត្វ ហើយបរិនិព្វានជាថ្មី ហៅថា "**ធាតុនិព្វាន**" ។ល។

នេះគឺនិព្វានខាងភាសា បរិយត្តិធម៌ ឬភាសាប្រកួត សឹងមានយ៉ាងសម្បូណ៌, តែគ្មានទាក់ទងដល់ការប្រតិបត្តិគឺមានមកត្រឹមតែជារឿងរបស់អ្នកប្រាជ្ញ ខាងផ្លូវលេងសំដី, ខាងផ្លូវបកស្រាយផ្នែកបរិយត្តិធម៌ប៉ុននោះ ។ ភាសាអំនួតបែបនេះ, អ្នកប្រតិបត្តិធម៌ដើម្បីនិព្វានពិតៗ មែនៗ មិនចាំបាច់គិតគូរដល់ក៏បាន ។ បេក្ខជននិព្វានគួរប្រកាន់យកន័យរបស់និព្វាន ត្រឹមតែជាភាពត្រជាក់ត្រជុំប៉ុននឹងបានហើយ ប្រសិនបើពង្រីកអោយធំ ឬពោលអោយវែងជាងនេះ ក៏គឺភាពត្រជាក់ដែលកើតមានឡើង ព្រោះអស់ភ្លើងទុក្ខ ភ្លើងកិលេសហ្នឹងឯង ។ ព្រោះអ្វី? ព្រោះភាពត្រជាក់ជាភាវៈនៃនិព្វាន គ្រឿងធ្វើអោយភាពត្រជាក់ ជាទំរើនៃនិព្វាន អាការរំលត់កំដៅហើយស្ថាបនា



Websites: WatKhemaraRatanaram.org or WatKhmers.org

ភាពត្រជាក់ ជាកិរិយារបស់និព្វាន ។ ក្នុងន័យថា គឺជាភាពត្រជាក់, ភាពអស់ទុក្ខ ភាពចប់ជីវិតអន្ទោលហ្នឹងឯង ។

អ្នកអានបានដឹងរឿងនិព្វានគួរសមដែរហើយ, ក្នុងឃ្លានេះ, អ្នកសរសេរសូមអោយចម្លើយ ចំពោះសំនួរថានិព្វាននៅឯណា ដែលបានធ្វើសំនេរមកហើយ ។ ដើម្បីដឹងជាបន្ទាន់ អ្នកអានគប្បីធ្វើការកត់សម្គាល់ថា អ្នកសម្រេចនិព្វាននៅក្នុងទីណា និព្វាននៅក្នុងទីនោះ ព្រោះនិព្វានជាភាពមាននៅ គ្រប់ទិសទីក្នុងសកលលោក, បើអ្នកបានសម្រេចនិព្វាននៅក្នុងកាមលោក និព្វាននៅក្នុងកាមលោក បើអ្នកបានសម្រេចនិព្វាននៅក្នុងរូបលោក និព្វាននៅក្នុងរូបលោក បើអ្នកបានសម្រេចនិព្វាននៅក្នុងអរូបលោក និព្វាននៅក្នុងអរូបលោក ។ល។ ព្រោះអ្វី? ព្រោះថា និព្វានជាជាតុគ្មានលំនៅ គ្មានទំរ គ្មានតំណាំង ជាទឹកដីភ្លើងខ្យល់ ឬជាអាកាសវិញ្ញាណ អាកិញ្ចញ្ញានេវសញ្ញានាសញ្ញា ។ល។ ឡើយ ។ ជាមួយគ្នានេះ និព្វានមិនមែនជាតួលោកដែលយើងកំពុងរស់នៅសព្វថ្ងៃនេះ, មិនមែនជាតួសកលលោក ដែលយើងពុំទាន់បានស្គាល់ ពុំទាន់បានទៅដល់ ។ មិនមែនជាអាទិត្យ, ចន្ទ, អង្គារ, ពុធ, ព្រហស្បត៍, សុក្រ, សៅរ៍ ។ល។ មិនមែនជាដំណើរទៅ មិនមែនជាដំណើរមក មិនមែនជាការឋិតនៅ, មិនមែនជាកិរិយាកើត, មិនមែនជាកិរិយាចុត្តិ មិនមែនជាអារម្មណ៍ទាំងឡាយ ដែលយើងធ្លាប់ស្គាល់ក្នុងលោកនេះ, មិនមែនជាភាពវែង, ភាពខ្លី, មិនមែនជាភាពធំ, ភាពតូ, មិនមែនជារូបនិងអរូប ។ល។ តែជានិព្វានហ្នឹងតែម្តង ។ ក្នុងន័យថានិព្វានគឺជានិព្វាន



Websites: WatKhemaraRatanaram.org or WatKhmers.org

មាននៅគ្រប់ទិសទីក្នុងសកលលោក ប៉ុន្តែជានិព្វានវិស័យ មិនមែនជាលោកវិស័យឡើយ ។ ចំពោះរឿងនេះ អ្នកប្រាជ្ញខាងផ្នែកស្រាវជ្រាវលោក មានគំហើញថា លោកគឺជាលោក និព្វានគឺជានិព្វាន , សឹងមានភាពទំនាក់ទំនងប្រហាក់ប្រហែលទឹកនឹងប្រេង ដែលនៅក្នុងទីរួមគ្នា ឬ ជាមួយគ្នា តែមិនចូលគ្នា ( ទឹកនៅជាវិស័យទឹក ប្រេងនៅជាវិស័យប្រេង តាមភាពដើមដដែល )។ និព្វានពិត , គេត្រូវបានក្នុងលោក , ក្នុងជាតិនេះ ។ គឺកំដៅមាននៅក្នុងទីណា , គេត្រូវលត់កំដៅក្នុងទីនោះ , ភាពក្តៅនៅត្រង់ណា , ភាពត្រជាក់នៅត្រង់នោះ , ក្តៅកើតក្នុងទីណា ទីនោះគ្មានត្រជាក់ , ក្តៅរលត់ក្នុងទីណា ទីនោះកើតត្រជាក់ ។

បើតាមន័យនេះ និព្វានគឺគេត្រូវបានក្នុងជីវិតនេះ មិនមែនត្រូវបានក្នុងជីវិតខាងមុខទេ ប្រសិនបើរំលត់ភ្លើងកិលេសបាន។ ដោយន័យថា កំដៅកើតមានក្នុងជាតិណា ក្នុងទីណាពេលណា ត្រូវរំលត់ក្នុងជាតិនោះ ទីនោះ ពេលនោះ។ និយាយខ្លី គឺនិព្វានគេត្រូវបានសម្រេច ក្នុងពេលកំពុងរស់ , មិនមែនស្លាប់ហើយទើបត្រូវបានទេ ។ និព្វានក្នុងពុទ្ធសាសនា គឺជាធាតុដែលបុគ្គលត្រូវបានសម្រេចដោយគ្មានកំណត់កាល ( អកាលិកោ ) ។

និព្វានជារឿងរបស់មនុស្សរស់ មិនមែនជារឿងរបស់មនុស្សស្លាប់ទេ ។ និព្វានជារឿងដែលត្រូវដឹងចំពោះខ្លួន អ្នកដទៃពុំអាចដឹងជំនួសខ្លួនបានឡើយ ។ និព្វានគឺជាភាពត្រជាក់ ដែលកើតមានភ្លាមៗជាមួយនិងភាពរលត់ភ្លើងកិលេស ។ ភាពត្រជាក់គឺនិព្វាន គេត្រូវ



Websites: WatKhemaraRatanaram.org or WatKhmers.org

ស្វែងរកក្នុងភាពក្តៅ ។ កំដៅមាននៅក្នុងទីនេះ , ក្នុងជីវិតនេះ , ត្រូវរុករកក្នុងទីនេះ , ក្នុងជីវិតនេះ ។ ទីណាមិនប្រាកដដោយកិលេស ទីនោះជានិព្វាន គឺថាកិលេសមិនមាន , មិនប្រាកដក្នុងទីណា , និព្វានក្នុងទីនោះ , ប្រាកដក្នុងទីនោះ ។ និយាយមួយយ៉ាងទៀតថា សង្សារវដ្តមិនប្រាកដក្នុងទីណា និព្វានប្រាកដក្នុងទីនោះ ។

សេចក្តីសរុប៖ និព្វានជាចំនុចចុងផ្លូវរបស់សត្តា , ជីវិតសកលសត្វមួយណាក៏ដូចជាមួយណា រមែងវិវត្តទៅរកស្ថានៈនៃនិព្វានរឿយៗ ភាពផក់ស្រួបនៃនិព្វានហាក់មានមកលើមនុស្សគ្រប់កាលវេលា ។ សញ្ជាតញ្ញាណរបស់មនុស្សត្រូវការតស្សូរភាពជានិច្ច , តែត្រូវអំណាចទាំងឡាយមានផលកម្មជាដើម តាមដេញស្ទាក់ ស្កាត់រុញច្រានអោយឃ្លាតចេញអំពីផ្លូវពិតផ្លូវមែនរៀងរាល់ពេល ព្រោះខ្លួនជាសត្វភ្នែកខ្វាក់ មើលផ្លូវផុតន័យមិនឃើញ ស្ដាបនាទំរើរដោះខ្លួនចេញចាកទុក្ខមិនកើត។

ដំណើរឆ្លងចាកសង្សារវដ្ដៈ រូបកាយសត្វលោកប្រៀបដូចសំពៅ ។ ចិត្តវិញ្ញាណដូចនាយសំពៅ ។ សង្សារវដ្តដូចសកលសាគរ ។ សកលលោកឬត្រៃភព ដូចកំពង់ជំនួញ ។ ផលបុណ្យផលបាបក្នុងជាតិមួយៗ ដូចកំហាតនិងចំណេញនៃទំនិញ ដែលនាយសំពៅត្រូវបានក្នុងកំពង់មួយៗ ។ ដំណាល់កោះមួយៗ ឬ ត្រើយយ៉ាងកំពូល , យ៉ាងផុតភ័យ អស់ទុក្ខ នឹងបានសម្រេច , លុះត្រាបុគ្គលកើតក្តីពេញចិត្តបញ្ឈប់ទំរើចរាចរ ក្នុងសកលសាគរយ៉ាងស្ថាពរ , យ៉ាងដាច់ខាត គឺធ្វើយ៉ាងណាអោយសម្រេចនិព្វាន ។



Websites: WatKhemaraRatanaram.org or WatKhmers.org

សកលមនុស្ស គឺនាវិកនិងនាយសំពៅ កាលណានាំគ្នាស្រវឹងអំពីរឿងរូបឬតួសំពៅ គ្មានស្មារតីភ្ញាក់រលឹកគិតគូរដល់ចិត្តឬនាយសំពៅ សំពៅនឹងត្រូវរលកព្យុះខ្យល់បោកបក់ លង់លិច ក្នុងមហាសាគរ មុនពេលចូលចតកំពង់កោះ ដែលខ្លួនត្រូវការជាមិនខាន ។ តែបើសកលមនុស្ស ខំប្រឹងអនុវត្តនូវទំរើខាងផ្លូវចិត្តច្រើនហួសពេករហូតដល់ភ្លេចទំរើរបស់រូបកាយ ដែលជាលំនៅរបស់ចិត្ត ក៏ទៅមិនរួចដូចគ្នា ។ ដូចនេះ, ទើបព្រះបរមសាស្តាចារ្យបង្រៀនអោយដើរផ្លូវកណ្តាល គឺធ្វើយ៉ាងណាអោយចិត្ត និងកាយមានទំរើប្រហាក់ប្រហែលគ្នា, និងតឹងមួយធូរមួយ នៅលើបន្ទាត់ គឺអប្បមាទធម៌ ក្នុងក្របខ័ណ្ឌនៃបញ្ញាថ្នាក់វិបស្សនា ឬលោកុត្តរៈ ។

តាមសច្ចធម៌, យើងគ្រប់គ្នា គ្មានខ្លួន គ្មានប្រាណទេ ។ របស់ដែលមានគឺបញ្ចក្ខន្ធ ឬ " កាយ " និង " ចិត្ត " ដែលលោកប្រៀបប្រដូចទៅនឹង " សំពៅ " និង " នាយសំពៅ " ប៉ុននោះ ។ ចិត្តក៏មិនមែនជារបស់យើង ព្រោះថាកាលណាសម្រេចនិព្វានឬបានដល់កោះ គឺនិព្វាននោះ, ភាវៈនៃនិព្វានមិនមែនជាចិត្តទេ, តែចិត្តគ្រាន់តែជាភាពមួយ, ដែលបានពាល់ត្រូវនូវនិព្វាន ឬស្ថានៈនៃនិព្វានបានប៉ះពាល់ត្រូវចិត្តប៉ុននឹងឯង ។ និព្វានភាពមានពិតមានមែន, តែគ្មានអ្នកណាដឹងបាន ស្គាល់កើត ប្រសិនបើអវិជ្ជាមិនទាន់អស់អំពីខន្ធសន្តាន ។ លោកថាដូចពន្លឺព្រះអាទិត្យ កាលណាបើកបង្អួច យើងមើលឃើញ, កាលណាយើងបិទបង្អួច យើងមើលមិនឃើញ ។ ប៉ុន្តែពន្លឺរស្មី មិនមែនគ្មានទេ គឺមាននៅជាធម្មតា, ឬដូចរូបធាតុ,



Websites: WatKhemaraRatanaram.org or WatKhmers.org

សទ្ទធាតុ, គន្ធធាតុ, រសធាតុ, ផោដ្ឋព្វធាតុ ។ល។ ដែលមានពាសពេញទាំងអាកាសធាតុ, តែពុំបានប្រាកដដល់មនុស្សដែលគ្មានភ្នែកទិព្វ ។ល។ ព្រមគ្នានេះ គ្មានប្រាកដដល់វិស័យទាំងឡាយ មានទស្សនវិស័យជាដើមរបស់មនុស្ស ដែលគ្មានគ្រឿងប្រដាប់វិទ្យាសាស្ត្រសំរាប់ចាប់ ។

បញ្ចក្ខន្ធណា មានអវិជ្ជានៅខាងក្នុង, បញ្ចក្ខន្ធនោះរមែងមានឧបាទាន ។ បញ្ចក្ខន្ធមានឧបាទានដូចនេះ ពុំអាចសម្ពស្ស៍ ជាមួយនឹងនិព្វានបានទេ ។ បញ្ចក្ខន្ធបែបនេះ ពោរពេញទៅដោយទុក្ខ, ដោយភាពអន្ទោលវិលវល់ខ្ពស់ទាប, ទាបខ្ពស់, លិចអណ្តែតអណ្តែតលិច ក្នុងសង្សារវដ្តរឿយៗ គ្មានទីចប់ គ្មានទីបំផុត គ្មានទីអស់ហើយឡើយ ។

**បញ្ចក្ខន្ធ** ក្រោយមកពីបានប្រតិបត្តិធម៌ មានអវិជ្ជាឧបាទានអស់ហើយ ។ បញ្ចក្ខន្ធនេះគ្មានគេ, គ្មានយើង, គ្មានអញ, គ្មានឯង ។ល។ ជាបញ្ចក្ខន្ធមានភាពសមគួរដល់ទំរើសម្ពស្ស៍របស់ចិត្ត ជាមួយនឹងនិព្វាន ឬចូលដល់និព្វាន ដំណាលគ្នានេះ ចិត្តបេក្ខជននិព្វានបានទទួលរស គឺភាពត្រជាក់សែនត្រជាក់របស់និព្វានជាប្រាកដ ។

បញ្ចក្ខន្ធដែលមានអវិជ្ជាអស់ហើយ, តែមិនទាន់បែកធ្លាយ ឬមិនទាន់រលត់រលាយនៅឡើយ ។ បញ្ចក្ខន្ធនេះ ត្រូវបានផឹករសនិព្វានក្នុងជីវិតបច្ចុប្បន្ន ។ ភាវៈនៃនិព្វានដូចនេះ លោកហៅថា " សឧបាទិសេស " ។ កាលណាបញ្ចក្ខន្ធបែកធ្លាយ រលត់រលាយយ៉ាងគ្មានសំនល់, យ៉ាងអស់ដើង, កាលនោះរសយ៉ាងកំពូលនៃនិព្វាន



Websites: WatKhemaraRatanaram.org or WatKhmers.org

ដែលលោកអោយឈ្មោះថា "សេឯក" ឬ "សេទោល" គឺរសគ្មានអាស្រ័យបញ្ចក្ខន្ធនឹងមានក្នុងលំដាប់នោះ ។ ភាវៈនៃនិព្វានបែបនេះលោកហៅថា "អនុបាទិសេស" ឬ "ខន្ធបរិនិព្វាន" ។

ទំរើប្រតិបត្តិធម៌ជាន់ខ្ពស់ ឬ ទំរើអនុវត្តអរិយមគ្គ មានអង្គ៨ប្រការ ជាមួយនឹងបារមីធម៌១០យ៉ាង ដែលបានធ្វើសំនេរមកហើយ គឺជាទំរើស្ថាបនាផ្លូវ និងសង់ស្ពានដើរឆ្ពោះទៅកាន់និព្វាន ។

សកលសត្វ នៅជិត ឬ នៅឆ្ងាយ អំពីនិព្វានប៉ុនណា គ្មានអ្នកណាដឹងជំនួសអ្នកណាបានឡើយ ។ ដំណឹងអំពីនិព្វាន ត្រូវដឹងដោយខ្លួនឯង ។ ដូចនេះ ទើបព្រះសម្មាសម្ពុទ្ធបានមានពុំនោលថាធម្មៈទាំងឡាយរហូតដល់មាននិព្វានជាទីបំផុតនោះ ជាសន្ទិដ្ឋិកោ គឺអ្នកណាបាន , អ្នកនោះឃើញ ។ ( មើលសៀវភៅនិព្វានទស្សនៈ , សៀវភៅទស្សនសកលនិងសៀវភៅសកលចិន្តាប្រកបផង ) ៕

ចប់



Websites: WatKhemaraRatanaram.org or WatKhmers.org

# និព្វានទៅឯណា?



ភិក្ខុធម្មបាល ខៀវ ជុំ

ព.ស. ២៥១៧ គ.ស. ១៩៧៣

Websites: WatKhemaraRatanaram.org or WatKhmers.org